# مدرسة اهل البيت

# សាលា
# អាស្ហុល-បៃត៏

## សៀវភៅ ហ្វីកោ្ហះហ្ហ៍ ថ្នាក់ទី ៩

រ៉ស៊ូលុលឡោះហ្ហ៍ﷺមានព្រះវចនៈថា៖ "ការស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ចរបស់មុស្លីមីនប្រុសស្រីគ្រប់រូប ។"

## សិក្សាសាសនា

# បញ្ជីមាតិកា


មេរៀនទី ១ - ស៊ោំម៍(១) ........................................ ៤
មេរៀនទី ២ - ស៊ោំម៍(២) ........................................ ៧
មេរៀនទី ៣ - ស៊ោំម៍(៣) ........................................ ១១
មេរៀនទី ៤ - ស៊ោំម៍(៤) ........................................ ១៤
មេរៀនទី ៥ - ស៊ោំម៍(៥) ........................................ ១៨
មេរៀនទី ៦ - ស្វ៊ឡាត្ទុ អាល់-ក៊្វស្ស៊ូរ៍(១) ........................................ ២២
មេរៀនទី ៧ - ស្វ៊ឡាត្ទុ អាល់-ក៊្វស្ស៊ូរ៍(២) ........................................ ២៦
មេរៀនទី ៨ - ស្វ៊ឡាត្ទុ អាល់-ក៊្វស្ស៊ូរ៍(៣) ........................................ ៣០
មេរៀនទី ៩ - តាយ៉ាំមុម(១) ........................................ ៣២
មេរៀនទី ១០ - តាយ៉ាំមុម(២) ........................................ ៣៥
មេរៀនទី ១១ - ស្វ៊ឡាត្ទុ អាល់-អាយ៉ាត់ (صلاة الآيات) ........................................ ៣៨
មេរៀនទី ១២ - ស្ហាគីយ៉ាស្ទុ អាល់-ស្វ៊ឡាត្ទុ(១) ........................................ ៤១
មេរៀនទី ១៣ - ស្ហាគីយ៉ាស្ទុ អាល់-ស្វ៊ឡាត្ទុ(២) ........................................ ៤៤
មេរៀនទី ១៤ - ស្ហាគីយ៉ាស្ទុ អាល់-ស្វ៊ឡាត្ទុ(៣) ........................................ ៤៦
មេរៀនទី ១៥ - គ៊ុសល៍ ឬ គ៊ុស្ស៊ូល (ស្នានពិធីជម្រះបន្សុទ្ធ) ........................................ ៤៩
លំហាត់ ១ ........................................ ៥៦
លំហាត់ ២ ........................................ ៥៦
លំហាត់ ៣ ........................................ ៥៧
លំហាត់ ៤ ........................................ ៥៨
លំហាត់ ៥ ........................................ ៥៩
លំហាត់ ៦ ........................................ ៦០
លំហាត់ ៧ ........................................ ៦១
លំហាត់ ៨ ........................................ ៦២
លំហាត់ ៩ ........................................ ៦៣

**មេរៀនទី ១**

# ស៊ោម៍ (صوم) (១)

## ន័យរបស់ខែរ៉ម៉ាជូន

ខែរ៉ម៉ាជូនជាខែពិសិដ្ឋបំផុតក្នុងប្រក្រតិទិនអ៊ីស្លាម ហើយជាខែដែលនាំមកនូវសព្វសិរីសួស្តីផ្នែកសង្គម ផ្នែកសីលធម៌និងផ្នែកធម៌ ។ ឌូអាអ៊ុំខាងក្រោមនេះឆ្លុះបញ្ចាំងនូវពរជ័យសិរីសួស្តីមួយចំនួនរបស់ខែនេះ គឺ៖

*"អល់ឡោះហ៍ﷻអឺយ នេះគឺខែរ៉ម៉ាជូន ។ ក្នុងខែនេះឯងដែលព្រះអង្គបានចាត់បញ្ជូនគួរអានមក ជាមគ្គទេសក៍ដឹកនាំសម្រាប់មនុស្ស ជាសញ្ញាជាក់ច្បាស់មួយសម្រាប់ញែកការពិតចេញពីវិរុទ្ធភាព ជាខែកាន់ត្រណមអាហារ ជាខែបំពេញការបួងសួង ជាខែសម្រាប់បែរមករកព្រះអង្គﷻ និងជាខែសូមស្មារលាកំហុស ។ ជាខែអត់ឱនទោស និងអនុគ្រោះលោះលា ។ ជាខែដែលមាន "យប់ អាល់-កូដ្រ៍" ដែលជាយប់ប្រសើរលើស ១០០០ ខែ ។ អល់ឡោះហ៍អឺយ សូមព្រះអង្គជូនពរជ័យសិរីសួស្តីដល់មូហាំម៉ាដ់ ព្រមទាំងបណ្តាកូនចៅរបស់ព្រះអង្គផង ។ សូមព្រះអង្គឲ្យទូលព្រះបង្គំជាខ្ញុំបានទំនេរដើម្បីគោរពបូជាព្រះអង្គនិងសូត្រព្រះគម្ពីរ ។"*

ក្នុងចំណោមពរជ័យសិរីសួស្តីរបស់ខែនេះមាន គួរអាន យប់ឡៃឡាទុល-កូដ្រ៍ ការសូមស្មារលាកំហុស ការយោគយល់គ្នាទៅវិញទៅមក និងខមាទោសឲ្យគ្នា ។

យោលតាមជំនឿមុស្លីម ទង្វើនីមួយៗ ល្អក្តី អាក្រក់ក្តី មានទម្ងន់ជាងគេក្នុងខែនេះ ។ ដូច្នេះ បរិច្ចាគទានជាធម៌ដ៏ប្រសើរមួយគ្រប់ពេល តែវាជាធម៌ប្រសើរលើសសព្វមួយដងក្នុងខែនេះ ។ អំពើទុច្ចរិតជាបាបគ្រប់ពេលវេលា តែវាជាបាបកាន់តែធំក្នុងខែនេះ ។ គេបានផ្តាំផ្ញើឲ្យសូត្រគួរអានពេញមួយឆ្នាំ តែសូត្រគួរអានក្នុងខែរ៉ម៉ាជូនសំខាន់លើសនោះទៅទៀត ។

ព្រះសាស្តាﷺមានព្រះវចនៈថា៖ "សព្វអ្វីៗសុទ្ធតែមាននិទាយៈរដូវរបស់វា ឯ

និទាឃៈរដូវរបស់គួរអានគឺខែរ៉ម៉ាដន ។"

ពេលយប់មិអ៏រ៉ាច្ជ ព្រះសាស្ដាﷺបានសួរអល់ឡោះហ្វ៍عزوجلថា អ្វីទៅរង្វាន់របស់សីលត្រណមអាហារ ? អល់ឡោះហ្វ៍عزوجلបានតបព្រះអង្គﷺថា៖

*"កាន់សីលត្រណមអាហារនាំទៅរកគតិប្រាជ្ញា គតិប្រាជ្ញានាំឲ្យអ្នកយល់ដឹងសញ្ញា និងគោលដៅទាំងឡាយរបស់អញ ។ វានឹងដឹកនាំអ្នកទៅកាន់ដំណាក់ការជឿជាក់ក្នុងចិត្ត ។ ពេលណាបុគ្គលបានទៅដល់ដំណាក់ការជឿជាក់ប្រាកដ បុគ្គលនោះប្រុសឬស្រី នឹងមិនបារម្ភទៀតឡើយអំពីសេចក្ដីសម្បូរហូរហៀរ ឬសេចក្ដីអត់ឃ្លាន ។" (ប៊ីហ្ការ អាល់-អាន់វ៉ារ ប្ញាខ្ទីស្ស ៧៧)*

ពេលខែរ៉ម៉ាដនមកដល់ អ៊ីម៉ាំ ស៊ែនុល អាប៊ីឌីនعليه السلامបានបួងសួងថា៖

*"អល់ឡោះហ្វ៍អើយ សូមព្រះអង្គជួយអស់ទូលព្រះបង្គំជាខ្ញុំឲ្យបានកាន់សីលត្រណមអាហារ ដោយហាមឃាត់អវយវៈអស់ទូលព្រះបង្គំជាខ្ញុំប្រព្រឹត្តអំពើដែលមិនសព្វព្រះហឫទ័យព្រះអង្គ និងដោយដឹកនាំអវយវៈនោះទៅរកអំពើដែលធ្វើឲ្យព្រះអង្គទ្រង់សព្វព្រះហឫទ័យ... កុំឲ្យអស់ទូលព្រះបង្គំជាខ្ញុំបានឮនូវសម្ដីឥតខ្លឹមសារ កុំឲ្យអស់ទូលព្រះបង្គំជាខ្ញុំបានឃើញនូវអ្វីដែលធ្វើឲ្យភ្លេចព្រះអង្គ កុំឲ្យដៃអស់ទូលព្រះបង្គំជាខ្ញុំប្រព្រឹត្តនូវអំពើដែលព្រះអង្គបានហាម និងកុំឲ្យជើងអស់ទូលព្រះបង្គំជាខ្ញុំឈានទៅរកអ្វីដែលត្រូវហាម ។ (ស្វ៉ហ៊ីហ្វាស្ស អាល់-កាមីឡាស្ស)*

ព្រះសាស្ដាﷺយើងបានប្រាប់យ៉ាបៀរ ប៊ិន អាប់ឌុលឡោះហ្វ៍ថា៖

*"យ៉ាបៀរអើយ នេះគឺខែរ៉ម៉ាដន អ្នកណាតមអាហារក្នុងអំឡុងពេលថ្ងៃ ឈរក្នុងអំឡុងពេលយប់ ដើម្បីគោរពបូជាអល់ឡោះហ្វ៍ គ្រប់គ្រងអាការស្រេកឃ្លានរបស់ខ្លួន គ្រប់គ្រងចំណង់និងសំដីរបស់ខ្លួន អ្នកនោះនឹងឆ្លងផុតទៅដោយជ្រះអស់ពីបាប ដូចខែនេះបានឆ្លងផុតទៅដែរ ។" យ៉ាបៀរបានថា៖ "រ៉ស៊ូលុលឡោះហ្វ៍ﷺអើយ នេះគឺដំបូន្មានអស្ចារ្យមែន !" រ៉ស៊ូលុលឡោះហ្វ៍ﷺមានព្រះវចនៈថា៖ "លក្ខខណ្ឌសំខាន់បំផុត !" (អ៊ូស្វ៊ូល អាល់-កាហ្វី ក្បាលទី ៤)*

## តម្លៃរបស់ខែរ៉ម៉ាជូន

១. ខែរ៉ម៉ាជូនជាខែដែលពិសិដ្ឋបំផុត ដែលប្រកបដោយសិរីសួស្តីក្នុងប្រក្រតិទិនអ៊ីស្លាម ។
២. ព្រះគម្ពីរគួរអានត្រូវដាក់ចុះមកឲ្យព្រះសាស្តាមូហាំម៉ាដ់ﷺក្នុងខែនេះ ។
៣. អល់ឡោះហ្ទ៏عزّ وجلّទ្រង់លើកទោសឲ្យយើងបើយើងសូមខមាទោសព្រះអង្គعزّ وجلّ ។
៤. អល់ឡោះហ្ទ៏ទ្រង់ព្រមទទួលការសូមស្មារលាបាបទាំងឡាយដែរ ។
៥. យប់ឡៃឡាទុល-ក្ទដ៏រ៍នឹងប្រព្រឹត្តទៅក្នុងខែនេះ ដែលជាយប់ប្រសើរជាងយប់ធម្មតា ១០០០ ដង ។
៦. ឌូអាុអ៊ំនានានឹងត្រូវទទួលយ៉ាងងាយៗ ឥតបញ្ហា ។

**មេរៀនទី ២**

# ស្អៅម៍ (صوم) (២)

**មូលហេតុដែលយើងកាន់សីលត្រណមអាហារ**

១. អ៊ីស្លាមបានដាក់មកលើប្រុសស្រីគ្រប់រូបដែលគ្រប់អាយុ ឲ្យកាន់សីលត្រណមអាហារជាចាំបាច់ ។

២. ក្នុងគោលបំណងកំចាត់សភាវគតិអាក្រក់របស់យើង និងដើម្បីធ្វើឲ្យយើងដឹងខ្លួនថាយើងមានឆន្ទៈអាចចៀសវាងបានពីទង្វើ ដែលអាចធ្វើឲ្យការកាន់សីលត្រណមអាហារយើងទៅជាមោឃៈបាន ពេលណាយើងប្រព្រឹត្តទង្វើនីមួយ ។ សីលត្រណមអាហារពង្រឹងឆន្ទះយើងឲ្យរឹងមាំដើម្បីទប់ទល់អំពើហ្វារ៉ាំ អាស្រ័យហេតុនេះយើងនឹងមិនប្រព្រឹត្តបាបទេ ។

៣. បង្កើតនូវសាមគ្គីភាពរវាងអ្នកនិងអ្នកជិតខាងអ្នក ។ ក្នុងពេលដែលអ្នកកាន់សីលត្រណមអាហារ អ្នកដឹងថាមានអ្នកឯទៀតកាន់សីលត្រណមអាហារដែរនៅក្បែរអ្នក ។ ពេលអ្នកផ្តាច់សីលត្រណមអាហារ(អ៊ីហ្វត្វារ) អ្នកឯទៀតធ្វើដូច្នេះដែរ ។ ដូច្នេះ វាធ្វើមាននូវស្មារតីភាតរភាព ។

៤. ពេលណាអ្នកឃ្លាន ពេលនោះអ្នកដឹងថាជនទ័លក្រទ្រាំឃ្លានប៉ុណ្ណាខ្លះ ព្រោះតែមិនអាចរកចំណីបានរៀងរាល់ថ្ងៃ ហើយសីលត្រណមអាហាររបស់អ្នកជម្រុញឲ្យអ្នករិះគិតថាត្រូវធ្វើអ្វីខ្លះដើម្បីពួកគេនោះ ។ តែគួរឲ្យស្តាយ យើងតែងតែភ្លេចខ្លួនពាក់ព័ន្ធនឹងអាការស្រេកឃ្លានរបស់យើង ក្នុងពេលអ៊ីហ្វត្វារ ពេលដែលយើងហូបច្រើនដើម្បីជួសត្រណមអាហារយើង ។ ដូច្នេះហើយបានជាព្រះសាស្តាយើងﷺបានផ្តែផ្តាំឲ្យយើងហូបដើម្បីតែបំបាត់អាការឃ្លាន កុំឲ្យលើសពីនោះ ។

**សីលត្រណមអាហារចាំបាច់ (វ៉ាយ៊ីប)**

១. កាន់សីលត្រណមអាហារក្នុងខែរ៉ម៉ាដូន ។
២. កាន់សីលត្រណមអាហារសង (ក៏ដ៏ قضى) ខែរ៉ម៉ាដូន ។
៣. កាន់សីលត្រណមអាហារចាំបាច់ដោយសារកាហ្វហ្វារ៉ោះត៍ (كفارة) ។
៤. កាន់សីលត្រណមអាហារសង (ក៏ដ៏ قضى) ជូសអ្នកស្លាប់ ជាកាតព្វកិច្ចចាំបាច់លើកូនប្រុសបងគេ ។
៥. កាន់សីលត្រណមអាហារសង បន្ទាប់ពីបានសច្ចា (نذر) បានស្បថ (قسم) បានធ្វើកិច្ចព្រមព្រៀង (عهد) ។
៦. កាន់សីលត្រណមអាហារដែលបានដាច់ ឬចោលដោយចេតនា ។

## សីលត្រណមអាហារដោយស្ម័គ្រចិត្ត (ស៊ូណាត់)

១. រាល់ថ្ងៃរបស់ខែរ៉យ៉ាប់និងខែស្ហាក់បាន ឬយ៉ាងច្រើនបំផុតដែលអាចធ្វើបាន សូម្បីបីតែមួយថ្ងៃក៏ដោយ ។
២. ថ្ងៃទី ១៣ ថ្ងៃទី ១៤ ថ្ងៃទី ១៥ រៀងរាល់ខែតាមប្រក្រតិទិនចន្ទគតិ ។
៣. ថ្ងៃណៅរុស (ថ្ងៃទី ២១ ខែមីនា) ។
៤. ពីថ្ងៃទី ៤ ដល់ ថ្ងៃទី ៩ ខែស្ហៅវ៉ាល់ ។
៥. ពីថ្ងៃទី ២៥ និងថ្ងៃទី ២៩ ខែស៊ុលក្វក់ដ្ហាស់ (ذو القعدة) ។
៦. ថ្ងៃព្រហស្បត៏ដំបូងនិងថ្ងៃប្រហស្បត៏ចុងក្រោយរៀងរាល់ខែ ។ ថ្ងៃពុធដំបូងបង្អស់ក្រោយពីថ្ងៃទី ១០ រៀងរាល់ខែ ។
៧. ពីថ្ងៃទី ១ ដល់ថ្ងៃទី ៩ ខែស៊ុល-ហ៊ីច្ចយ៉ាស់ (ذو الحجة) ។
៨. ពីថ្ងៃទី ១៨ ខែស៊ុល-ហ៊ីច្ចយ៉ាស់ - អ៊ែដ្ឋ អាល់-ក៏ឌៀរ ។
៩. ថ្ងៃទី ២៤ ខែស៊ុល-ហ៊ីច្ចយ៉ាស់ - អ៊ែដ្ឋ អាល់-មូបាហ្វាឡាស់ ។
១០. ថ្ងៃទី ១ ថ្ងៃទី ៣ ថ្ងៃទី ៧ ខែមូហ្ការ៉ម ។
១១. ថ្ងៃទី ១៧ ខែ រ៉ប៊ីអ៊ុ អាល់-អៅវ៉ាល់ (ربيع الأول) - បុណ្យកំណើតព្រះសាស្តា ﷺ យើង ។
១២. ថ្ងៃទី ១៥ ខែយ៉ាម៉ាឌី អាល់-អៅវ៉ាល់ (جمادى الأول) ។
១៣. ថ្ងៃទី ២៧ ខែរ៉យ៉ាប់ - ថ្ងៃដែលអល់ឡោះហ្ ﷻ បានជ្រើសរើសព្រះសាស្តា ﷺ (بعثة) ។

អាចកាន់សីលត្រណមអាហារថ្ងៃផ្សេងៗទៀតក្នុងឆ្នាំបាន លើកលែងតែថ្ងៃដែលត្រូវហាមកាន់សីលត្រណមអាហារ ។ ថ្ងៃដែលត្រូវហាមនោះមានដូចតទៅគឺ៖

## ហាមកាន់សីលត្រណមអាហារ (ហ្ារ៉ាំ)

១. អ៊ីដ្ធ អ៊ុល-ហ្វីត្ទរី (عيد الفطر) ។
២. អ៊ីដ្ធ អ៊ុល អាដ្ហ៎ហ្ា (عيد الأضحى)
៣. កាន់សីលត្រណមអាហារក្នុងពេលឈឺ ។

## ការកាន់សីលត្រណមអាហារដែលគួរឲ្យស្អប់ (ម៉ាក់រ៉ុះហ្វ៍)

គេមិនផ្ដាំឲ្យកាន់សីលត្រណមអាហារក្នុងថ្ងៃទី ១០ ខែមូហ្ារ៉មទេ (ត្រូវនឹងថ្ងៃអ៊ាស៊ូរ៉អ៊ុ عاشوراء) ។

## លក្ខខណ្ឌដើម្បីកាន់សីលត្រណមអាហារ

១. មានសតិអារម្មណ៍គ្រប់គ្រាន់ ។
២. ជាមុសល្លីម ឬ ប្រតិបត្តិតាមច្បាប់អ៊ីស្លាម ។
៣. ស្ត្រីត្រូវផុតពីរដូវខែ (ហ្ៃដ្ហ៍ حيض និង នីហ្វាស نفاس) ពេញមួយថ្ងៃ ។
៤. មិនប្រថុយធ្លាក់ខ្លួនឈឺដោយសារសីលត្រណមអាហារទេ ។
៥. មិនមែនជាអ្នកធ្វើដំណើរទេ ។

ស្វ៉ម៍ជាទង្វើដែលឆ្លុះបញ្ចាំងនូវសេចក្ដីគោរពបូជា ។ គោលដៅរបស់វាគឺចៀសវាងប្រព្រឹត្តអំពើដែលត្រូវហាមដើម្បីសព្វព្រះហឫទ័យអល់ឡោះហ្វ៍ﷻ ដោយស្ដាប់បង្គាប់ព្រះអង្គﷻ ។

អ្វីដែលសំខាន់បំផុតគឺបំណង (នៀត) ។ មិនចាំបាច់ថាឮៗទេ ។ ក៏ប៉ុន្តែ ពេលអ្នកកាន់សីលត្រណមអាហារ អ្នកត្រូវតែចងចាំថាអ្នកធ្វើនេះដើម្បីសព្វព្រះហឫទ័យ

អល់ឡោះហ្វ៍ (គួរបាតាន់ អ៊ីលឡុលឡោះហ្វ៍) ។ អាចនៀតសម្រាប់មួយខែពេញតែម្តងក៏បានពីយប់មុនថ្ងៃដំបូងខែរ៉ម៉ាដ្ហន ឬ នៀតដាច់ឡែកពីយប់មុនថ្ងៃនីមួយៗ រៀងរាល់ថ្ងៃ ។ បើអ្នកជ្រើសរើសយករបៀបនៀតដំបូង ហើយបើអ្នកខានកាន់សីលត្រណមអាហារមួយថ្ងៃ អ្នកត្រូវនៀតឡើងវិញសាថ្មី ។

សីលត្រណមអាហារចាប់ផ្តើមពេលស្វ៉ឡាត់ស្វ៉ុបហ៊ ដែលហៅថា ស្វ៉ុបហ៊ ស្វ៉ឌិក ឬ ហ្វាច់រ៍ ។ ចប់នៅពេលស្វ៉ឡាត់ ម៉ាក់រីប ដែលប្រព្រឹត្តទៅក្រោយថ្ងៃលិចបន្តិច ។

**មេរៀនទី ៣**

# ស្វៅម៍ (صوم) (៣)

### អ្វីដែលធ្វើឲ្យសីលត្រណមអាហារមោឃៈ បើធ្វើដោយចេតនា

១. ស៊ី និង ផឹក ។
២. លើកដាក់លើអល់ឡោះហ្ទ៍ﷻ នូវអ្វីដែលមិនពិត លើព្រះសាស្តាﷺព្រះអង្គﷻ និង លើព្រះឧត្តរាធិការីعليهم السلامរបស់ព្រះសាស្តាﷺ ។
៣. បណ្តោយឲ្យធូលីហុយចូលដល់ក្នុងបំពង់ក ។
៤. មុជក្បាលលិចអស់ទៅក្នុងទឹក ។
៥. មិនបានងូតទឹកគុុសល៍ (ឬ គ្ហ៊ុស្វូល) រ៉ាយ៉ាប៊ីបមុនអាស្ទាន* ។

*នៅក្នុងសភាពមិនបរិសុទ្ធដោយចេតនា ពេលមានយ៉ាណាបាស្ទ ហៃ្វជ្ទ៍ ឬ និហ្វាស រហូតដល់ពេលស្វ៍ឡាត់ហ្វាច់រ៍ (ស្វ៊ុបហ៊ុ៍ ស្វ៍ឌិក្វ) ក្នុងខែរ៉ម៉ាដ្ធន ឬ ពេលក្វ៍ឌ្ធ៍ខែរ៉ម៉ាដ្ធន ។

៦. ចង្អោរ ។
៧. រួមភេទ ។
៨. ប្រព្រឹត្តអ្វីមួយដែលបណ្តាលឲ្យចេញទឹកកាម ។

### អ្វីដែលត្រូវចៀសវាងក្នុងពេលកាន់សីលត្រណមអាហារ

១. បន្តក់វត្ថុរាវក្នុងភ្នែកដែលអ្នកអាចស្គាល់រសជាតិឬក្លិនបានក្នុងបំពង់ក ។
២. ធ្វើអ្វីមួយដែលអាចធ្វើឲ្យអ្នកអន់ថយកម្លាំងកាយ ។
៣. ទុកសំពត់ទទឹកលើខ្លួនដើម្បីរក្សាអាកាសត្រជាក់ ។
៤. ហិតក្លិនក្រអូបរបស់រុក្ខជាតិឬផ្កា ។

៥. ដកធ្មេញ អំពើផ្សេងៗដែលបណ្តាលឲ្យចេញឈាម ។
៦. ប្រើប្រាសទទឹកដុសធ្មេញ ។
៧. ដាក់ទឹកក្នុងមាត់ ឬ ខ្ពុរមាត់ឥតចាំបាច់ ។

ទង្វើទាំង ៧ នេះមិនធ្វើឲ្យសីលត្រណមអាហាររបស់អ្នកមោឃៈទេបើអ្នកធ្វើ តែគប្បីចៀសវាង ។

## បុគ្គលដែលរួចខ្លួនពីការកាន់សីលត្រណមអាហារ

មានពីរប្រភេទ គឺៈ

ក) អ្នកដែលមិនកាន់សីលត្រណមអាហារហើយមិនក្ហ្ជ៏ ។
ខ) អ្នកដែលក្ហ្ជ៏នៅពេលក្រោយ ពេលខែរ៉ម៉ាដូនផុត ។

១. បុរសនិងស្ត្រីដែលមិនមានសមត្ថភាពកាន់សីលត្រណមអាហារបាន ព្រោះមានវ័យជរា រួចខ្លួនពីការកាន់សីលត្រណមអាហារទាំងស្រុង ។ មិនបាច់ក្ហ្ជ៏នៅពេលក្រោយទេ ។

២. មនុស្សជរាដែលពិបាកខ្លាំងក្នុងការកាន់សីលត្រណមអាហារ ត្រូវរួចខ្លួនដែរតែត្រូវ "សង" (ហ្វីដ្យយ៉ាស្ល់ الفدية) ទៅលើជនក្រីក្រនិងជនទ័លក្រខ្លាំង នូវមួយចំនួនភោជនាហារ (ប្រមាណ ៣/៤ គីឡូក្រាម) ជួសត្រណមអាហារនីមួយៗ ។ យកល្អឲ្យបរិច្ចាគស្រូវសាលីឬស្រូវស្រងែ ។

៣. បុគ្គលដែលមិនអាចទ្រាំអាការស្រេកទឹកបានព្រោះតែមានជម្ងឺ ត្រូវរួចផុតពីការកាន់សីលត្រណមអាហារ ។ ក៏ប៉ុន្តែ អាស្រ័យលើមូលហេតុពិសិដ្ឋរបស់ខែ នេះ បុគ្គលនោះ មិនត្រូវរម្ងាប់អាការស្រេកទឹកនោះទាល់តែបាត់ស្រេកទេ ។ បុគ្គលនេះត្រូវបង់ហ្វីដ្យយ៉ាស្ល់ជួសត្រណមនីមួយដែលបានខាន ហើយត្រូវក្ហ្ជ៏ពេលជាពីជម្ងឺ ។

៤. ស្ត្រីមានផ្ទៃពោះជិតសម្រាលហើយ មិនកាន់សីលត្រណមអាហារទេ បើសីលត្រណមនេះធ្វើឲ្យមានគ្រោះថ្នាក់ដល់កូនក្នុងពោះឬដល់ខ្លួនឯងផ្ទាល់ ។ ត្រូវបង់ហ្វីដ្យ៉ាស្ជួសសីលត្រណម ហើយក៏ដ្ជុំនៅពេលក្រោយ ។

៥. ម្ដាយដែលបំបៅកូនមិនកាន់សីលត្រណមអាហារទេ បើខ្លាចខ្វះទឹកដោះឲ្យកូនបៅ ។ ត្រូវសងហ្វីដ្យ៉ាស្ជួសត្រណមអាហារនីមួយៗដែលខ្លួនខាន ហើយត្រូវក៏ដ្ជុំនៅពេលក្រោយ ។

៦. ស្ត្រីដែលនៅក្នុងរយៈពេលរដូវខែមិនកាន់សីលត្រណមអាហារទេ ។ ការពិត គេហាមស្ត្រីកាន់សីលត្រណមអាហារក្នុងរយៈពេលមានរដូវខែ ។ ត្រូវក៏ដ្ជុំនៅពេលក្រោយ ។

**មេរៀនទី ៤**

# ស៊ៅម៍ (صوم) (៤)

**កាហ្វ៌ហ្វារ៉ោះត៍** (كفارة)

ស៊ី ផឹក ឬប្រព្រឹត្តអំពើណាមួយដោយចេតនា ដែលធ្វើឲ្យសីលត្រណមអាហារ មោឃៈ ដោយគ្មានមូលហេតុ ក្នុងខែពិសិដ្ឋរ៉ម៉ាដូន ជាបាបធំមួយ ។

បុគ្គលណាមិនកាន់សីលត្រណមអាហារ ដោយចេតនា បុគ្គលនោះត្រូវកាន់សីលត្រណមអាហារក៏ដូចនិងសងកាហ្វ៌ហ្វារ៉ោះត៍ ។ កាហ្វ៌ហ្វារ៉ោះត៍សីលត្រណមអាហារ គឺៈ

ក) លែងទាសៈម្នាក់ ។
ខ) ឬ កាន់សីលត្រណមអាហារ ៦០ ថ្ងៃ ។
គ) ឬ ឲ្យអាហារដល់ជនក្រីក្រ ៦០ នាក់ ។

បើអ្នកជ្រើសរើសយកកាន់សីលត្រណមអាហារ ២ ខែ អ្នកគប្បីកាន់សីលត្រណមអាហារ ៣១ ថ្ងៃជាប់ៗគ្នា បន្ទាប់មក អ្នកអាចកាន់សីលត្រណមអាហារ ២៩ ថ្ងៃដែលនៅសល់នោះ បានតាមសមត្ថភាពអ្នក ។ ក៏ប៉ុន្តែអ្នកមិនត្រូវចាប់ផ្តើមក្នុងអំឡុងពេលកាន់ត្រណម កាហ្វ៌ហ្វារ៉ោះត៍ ៣១ ថ្ងៃនោះទេ បើអ្នកដឹងច្បាស់ថាក្នុងអំឡុងពេល ៣១ ថ្ងៃជាប់ៗគ្នានោះនឹងមានថ្ងៃណាមួយដែលគេហាមកាន់ព្រណម (ហ្ញារ៉ាំ) ។ ឧទាហរណ៍ អ្នកមិនត្រូវចាប់ផ្តើមកាន់ត្រណមកាហ្វ៌ហ្វារ៉ោះត៍នៅដើមខែស៊្ហុល-ហ៊្ញិច្ចយ៉ាស់ (ذو الحجة) ទេ ព្រោះថ្ងៃទី ១០ ខែស៊្ហុល-ហ៊្ញិច្ចយ៉ាស់ (អ៊ីដ្ធ អ៊ុល អាដ្ហ៊ហ្ញា عيد الأضحى) គេហាមកាន់ត្រណម ។

បើអ្នកជ្រើសរើសយក ឲ្យអាហារដល់ជនក្រីក្រ ៦០ នាក់ អ្នកត្រូវបរិច្ចាគឲ្យគ្រប់ចំនួនអាហារសម្រាប់មួយពេលពេញ ជាស្រូវសាលី ឬជាស្រូវស្រងៃ ឬជាបាយ (ឬ

នំបុាំង) ។

ប្រសិនបើបុគ្គលណាផ្តាច់សីលត្រណមអាហារ ដោយប្រព្រឹត្តអំពើដែលត្រូវហាម ដូចជា ផឹកស្រា ទម្លាក់ពាក្យមិនពិតទៅលើអល់ឡោះហ៍ﷻ លើព្រះសាស្ដាﷺព្រះអង្គ ﷻ លើម៉ាក់ស្ហ៊ូមីនعليهم السلام បុគ្គលនោះត្រូវសងកាហ្ហ៍ហ្វារ៉ោះត៍ទាំង ៣ ប្រភេទ ។

## ច្បាប់(ហ៊ុកុម)កាន់សីលត្រណមអាហារក៏ហ្ផ៍

១. ក្នុងករណីដែលអ្នកត្រូវងូតទឹកគុ៏សល៍ (គុ៏ស៊ូល) មុនអាស្ហានស៊្វឡាត់ហ្វាច់រ៍ តែអ្នកមិនបានធ្វើ ពេលដែលអ្នកភ្ញាក់ពីដំណេកមួយដងក្នុងចន្លោះពេលនោះ អ្នកត្រូវកាន់សីលត្រណមក៏ហ្ផ៍ ។ តែបើអ្នកភ្ញាក់ពីដំណេកលើកទីពីរក្នុងចន្លោះពេលនោះ ហើយនៅតែមិនងូតទឹកគុ៏ស៊ូល អ្នកត្រូវកាន់សីលត្រណមក៏ហ្ផ៍ហើយ សងកាហ្ហ៍ហ្វារ៉ោះត៍ផង ។

២. ប្រសិនបើអ្នកណាធ្វើអ្វីមួយដែលបណ្តាលឲ្យដាច់ត្រណម ដោយមិនដឹងម៉ោង ស៊្វឡាត់ តែក្រោយមកបានដឹងថាម៉ោងស៊្វឡាត់ហ្វាច់រ៍បានចាប់ផ្តើមហើយ អ្នកនោះត្រូវក៏ហ្ផ៍ត្រណមនេះ ។ ដូចគ្នាដែរ ប្រសិនបើអ្នកនោះផ្តាច់ត្រណមដោយគិតថាដល់ម៉ោងហើយ តែក្រោយមកបានដឹងថាភាន់ច្រឡំ ។

៣. ប្រសិនបើអ្នកណាដាក់ទឹកក្នុងមាត់ដើម្បីឲ្យត្រជាក់ ឬ គ្មានមូលហេតុផ្សេង ហើយបានលេបទឹកនេះដោយអចេតនា អ្នកនោះត្រូវកាន់សីលត្រណមក៏ហ្ផ៍ ។

៤. ប្រសិនបើអ្នកណាផ្តាច់ត្រណមដោយមិនអាចចៀសវាងបាន អ្នកនោះត្រូវកាន់សីលត្រណមក៏ហ្ផ៍ ។

៥. ប្រសិនបើអ្នកណា "ឡប់ស្មារតី" រួចហើយមានស្មារតីគ្រប់គ្រាន់វិញ អ្នកនោះមិនចាំបាច់ កាន់សីលត្រណមក៏ហ្ផ៍ជួសត្រណមដែលខ្លួនបានអាក់ខានក្នុងពេលមានជម្ងឺនោះទេ ។

៦. ពេលណាអ្នកកាហ្វៀរទៅជាមុស្លីម ពេលនោះអ្នកកាហ្វៀរនោះមិនចាំបាច់ជួសសីលត្រណមអាហារដែលខ្លួនបានអាក់ខាន កាលពីខ្លួនបាននៅជាកាហ្វៀរនោះទេ ។ ក៏ប៉ន្តែ បើមុស្លីមណាបានផ្លាស់ប្តូរជំនឿ ទៅកាន់សាសនាផ្សេងបន្ទាប់មកបានត្រឡប់មកជាមុស្លីមវិញ អ្នកនោះត្រូវធ្វើក៏ដ្ហ៍ត្រណមទាំងអស់ដែលខ្លួនបានអាក់ខានក្នុងពេលដែលខ្លួនមិនមែនមុស្លីមនោះ ។

៧. ប្រសិនបើអ្នកណាផ្តាច់សីលត្រណមដោយបង្ខំ ពោលគឺ អ្នកនោះត្រូវផ្តាច់ត្រណមពីព្រោះជីវិតខ្លួនស្ថិតនៅក្នុងគ្រោះថ្នាក់ ដោយសារពួកកាហ្វៀរដែលនៅជុំវិញខ្លួន អ្នកនោះត្រូវធ្វើក៏ដ្ហ៍ត្រណមណាដែលខ្លួនបានអាក់ខាន ។

៨. ប្រសិនបើអ្នកណាមិនអាចកាន់សីលត្រណមជាប់បានក្នុងខែរ៉ម៉ាដ្ហន ដោយសមហេតុផល ឧទាហរណ៍ដោយសារមូលហេតុសុខភាព អ្នកនោះត្រូវសងវិញដោយកាន់សីលត្រណមក៏ដ្ហ៍ពេលណាខែរ៉ម៉ាដ្ហនចប់ តែឲ្យបានមុនខែរ៉ម៉ាដ្ហនថ្មី (គឺមុនឆ្នាំក្រោយ) ។ ក៏ប៉ុន្តែ បើអ្នកនោះមិនអាចធ្វើសងបានមុនឆ្នាំមុខទេ អ្នកនោះត្រូវផ្តល់អាហារ (៣/៤ គីឡូក្រាម) ដល់ជនក្រីក្រម្នាក់សម្រាប់រាល់ត្រណម (គឺចំនួនថ្ងៃ) ដែលខ្លួនបានអាក់ខាន ។ ក្រោយពីនេះទើបអ្នកនោះអាចធ្វើក៏ដ្ហ៍សីលត្រណមបាននៅពេលណាក៏បាន ។

៩. ប្រសិនបើអ្នកណាមិនកាន់សីលត្រណមអាហារទេក្នុងខែរ៉ម៉ាដ្ហន ដោយមូលហេតុសុខភាព ឬមូលហេតុណាមួយផ្សេងដែលសមហេតុផល ហើយក៏បានស្លាប់មុនចប់ខែរ៉ម៉ាដ្ហន មិនចាំបាច់កាន់សីលត្រណមក៏ដ្ហ៍ឲ្យអ្នកនោះទេ ។

១០. អ្នកដែលកាន់សីលត្រណមអាហារក៏ដ្ហ៍ខែរ៉ម៉ាដ្ហន អាចផ្តាច់ត្រណមមុនពេលស្ហ៊ុស្ហរ៍បាន (ដោយមិនបាច់សងកាហ្វ៍ហ្វារ៉ោះត៍) ។

១១. ប្រសិនបើអ្នកណាកាន់សីលត្រណមអាហារក៏ដ្ហ៍ឲ្យអ្នកស្លាប់ យកល្អកុំឲ្យអ្នកនោះផ្តាច់ត្រណមក្រោយពេលស្ហ៊ុស្ហរ៍ ។

១២. ក្រោយពីអ្នកណាម្នាក់ស្លាប់ កូនប្រុសបងគេរបស់អ្នកនោះគប្បីកាន់សីល

ត្រណាមអាហារក្ដីជំនួសអ្នកនោះ ។

១៣. ប្រសិនបើឪពុកមិនបានកាន់សីលត្រណាមអាហារវ៉ាយ៉ុប ផ្សេងពីសីលត្រណាមអាហារខែរ៉ម៉ាដូន ឧទាហរណ៍សីលត្រណាមអាហារដែលត្រូវធ្វើចំពោះការសច្ចាកូនប្រុសបងគេរបស់អ្នកនោះ ត្រូវកាន់សីលត្រណាមអាហារក្ដីជំនួសអ្នកនោះ ។ ប្រសិនបើឪពុកបាន ទទួលប្រាក់ឈ្នួលដើម្បីកាន់សីលត្រណាមអាហារក្ដីជំនួឲ្យអ្នកណាម្នាក់ហើយខានធ្វើទៅវិញ កូនប្រុសបងគេមិនចាំបាច់កាន់សីលត្រណាមអាហារនោះទេ ។

១៤. ប្រសិនបើអ្នកណាមានជម្ងឺច្រើនឆ្នាំហើយ ក្រោយពីបានជាវិញ អ្នកនោះត្រូវកាន់សីលត្រណាមអាហារទាំងអស់ក្ដីជំនួសម្រាប់ឆ្នាំដែលបានកន្លងទៅ ហើយផ្ដល់អាហារ (៣/៤ គីឡូក្រាម) ដល់ជនក្រីក្រម្នាក់សងរាល់សីលត្រណាម (គឺសងចំនួនថ្ងៃ) ដែលបានអាក់ខាន ។

**មេរៀនទី ៥**

# ស៊ោម៍ (صوم) (៥)

**ច្បាប់(ហ៊្វូកុម)ដែលត្រូវអនុវត្តិតាមក្នុងពេលធ្វើដំណើរ**

១. ធ្វើដំណើរមានន័យថាទៅដល់ព្រំប្រទល់ក្រៅរបស់ស្រុកឬភូមិ ទៅកាន់ទីដៅដែលមានចម្ងាយមិនតិចជាង ៤៥ គីឡូម៉ែត្រ ។ ថ្ងៃដែលអ្នកចង់ធ្វើដំណើរ អ្នកនឹងមិនដាច់ត្រណមនៅឯផ្ទះអ្នកឬនៅក្នុងស្រុកអ្នកទេ តែនៅពេលដែលអ្នកបានចេញផុតពីព្រំដែនស្រុកដែលអ្នករស់នៅ ។

២. អ្នកមិនត្រូវទុកត្រណមអាហារនៅឯកន្លែងដែលអ្នកបំពេញស្វ៍ឡាត់ អាល់-កូស្វ៍រ (ស្វ៍ឡាត់អ្នកដំណើរ) ទេ ។ ប្រសិនបើអ្នកធ្វើដំណើរទៅកាន់កន្លែងណាមួយដែលអ្នកចង់ស្នាក់នៅតិចជាង ១០ ថ្ងៃ អ្នកនឹងបំពេញស្វ៍ឡាត់អាល់-កូស្វ៍រ (ស្វ៍ឡាត់អ្នកដំណើរ) សម្រាប់ស្វ៍ឡាត់ ៤ រ៉ក់អាត់ ហើយអ្នកមិនកាន់សីលត្រណមអាហារទេ ។ អ្នកនឹងក្ហ៍ដ៍នៅពេលក្រោយ ។

៣. អ្នកណាដែលមានមុខរបរតម្រូវឲ្យធ្វើដំណើរ (ឧទាហរណ៍ អ្នកបើកបររថយន្តយន្តហោះ អ្នកបម្រើតាមរថយន្ត ឬយន្តហោះ) ឬ អ្នកដែលធ្វើដំណើរក្នុងគោលបំណងប្រព្រឹត្តអំពើដែលត្រូវហាម (គឺធ្វើអំពើបាប) ត្រូវតែកាន់សីលត្រណមអាហារក្នុងពេលធ្វើដំណើរ ហើយបំពេញស្វ៍ឡាត់តាមធម្មតា (មិនឲ្យបំពេញស្វ៍ឡាត់អាល់-កូស្វ៍រទេ) ។

៤. គេអនុញ្ញាតឲ្យធ្វើដំណើរក្នុងគោលបំណងគេចវេះកាន់សីលត្រណមអាហារ តែគប្បីចៀសវាង ។

៥. ប្រសិនបើអ្នកធ្វើដំណើរពីផ្ទះអ្នកក្រោយពេលស្ហ៊ុស្វ៍រ អ្នកត្រូវកាន់សីលត្រណមអាហារលុះចប់ ។ ក៏ប៉ុន្តែ បើអ្នកចាកចេញពីផ្ទះមុនពេលស្ហ៊ុស្វ៍រ អ្នកកុំកាន់សីល

ត្រណមអាហារ ។

៦. ថ្ងៃដែលអ្នកត្រឡប់មកវិញ បើអ្នកមកដល់ព្រំប្រទល់ស្រុកដែលអ្នករស់នៅមុនពេលស្ហ៊ុស្វរ៍ ហើយអ្នកមិនបានធ្វើអ្វីមួយដែលបណ្ដាលឲ្យត្រណមអ្នកដាច់ទេ អ្នកត្រូវទុកត្រណមនេះសម្រាប់ថ្ងៃនេះ (គឺធ្វើឲ្យចប់)។ បើអ្នកមកដល់ព្រំប្រទល់ស្រុកដែលអ្នករស់នៅក្រោយពេលស្ហ៊ុស្វរ៍ អ្នកកុំកាន់ត្រណមអាហារ ហើយអ្នកធ្វើក្ហ៍ដ្ហ៍ក្រោយខែរ៉ម៉ាដ្ហន ។

៧. ប្រសិនបើអ្នកណាចង់កាន់សីលត្រណមអាហារស្ងណាត់ថ្ងៃណាមួយ ថ្ងៃនោះអ្នកនោះត្រូវធ្វើដំណើរ អ្នកនោះអាចកាន់សីលត្រណមអាហារបាន ព្រោះអ្នកនោះបានប៉ងថានឹងកាន់សីលត្រណមថ្ងៃនោះជាពិសេស ។ ប្រើច្បាប់នេះបានដែរសម្រាប់អ្នកណាដែលបានប៉ងនឹងកាន់ត្រណម ដោយកំណត់ថ្ងៃណាមួយយ៉ាងច្បាស់លាស់ទោះបីអ្នកនោះធ្វើដំណើរ ឬមិនធ្វើដំណើរក៏ដោយក្នុងថ្ងៃនោះ ។ ក៏ប៉ុន្តែ បើអ្នកណាប៉ងកាន់សីលត្រណមអាហារ តែមិនបានកំណត់ថ្ងៃទេ អ្នកនោះមិនអាចកាន់សីលត្រណមបានទេបើអ្នកនោះធ្វើដំណើរក្នុងថ្ងៃនោះ ។

៨. អ្នកធ្វើដំណើរអាចកាន់សីលត្រណមអាហារនៅឯម៉ាឌ្ហីណាស្ងអស់ ៣ ថ្ងៃបាន ប្រសិនបើអ្នកនោះមានគោលបំណងចង់សម្រេចសេចក្ដីប្រាថ្នារបស់ខ្លួន ។ ក្នុងករណីនេះ គប្បីកាន់ត្រណមថ្ងៃពុធ ព្រហស្បតិ៍ និងសុក្រ ។

៩. ប្រសិនបើអ្នកធ្វើដំណើរណាបានដឹងនៅក្នុងពេលថ្ងៃ ថាអ្នកធ្វើដំណើរមិនមានសិទ្ធិកាន់សីលត្រណមអាហារទេនោះ សីលត្រណមអាហាររបស់អ្នកនោះទៅជាមោឃៈ ។ ក៏ប៉ុន្តែ បើអ្នកនោះបានដឹងក្រោយពីថ្ងៃលិច សីលត្រណមអាហាររបស់អ្នកនោះមិនខូចទេ ។

## ពេលមើលឃើញខែ

### ខែថ្មី

ពេលណាខែទៀបនឹងនៅក្នុងចន្លោះផែនដីនិងថ្ងៃ ពេលនោះគេរាប់ពេលនេះថាជាដំណាក់កាលរបស់ខែថ្មី ។ ពេលនេះខាងងងឹតរបស់ខែបែរមករកផែនដី ។ ហេតុនេះឯងបានជាគេមើលមិនឃើញខែថ្មី ។ ថ្ងៃនិងម៉ោងរបស់ខែថ្មីដែលគេមើលមិនឃើញនេះមានចារនៅក្នុងកាសែតនិងប្រក្រតិទិនជាធម្មតា ។

ខែអ៊ីស្លាមចាប់ផ្តើមនៅពេលមើលឃើញចំណិតខែដំបូងបង្អស់ មិនចាប់ផ្តើមដោយផ្អែកលើខែថ្មីដែលមើលមិនឃើញនោះទេ ។ តាមធម្មតាគេមើលឃើញចំណិតខែលើមេឃប៉ែកខាងលិច បន្ទាប់ពីថ្ងៃលិច ក្នុងយប់ទីមួយឬក្នុងយប់ទីពីរក្រោយដំណាក់កាលខែថ្មី ។ ការមើលឃើញអាស្រ័យលើអាយុកាលរបស់ចំណិតខែ លើពេលវេលាក្នុងចន្លោះថ្ងៃលិចនិងខែលិច និងអាស្រ័យលើចម្ងាយមុមរវាងថ្ងៃនិងខែ ។

ចូរកុំច្រឡំខែថ្មីជាមួយចំណិតខែស្តើងដែលគេអាចមើលឃើញនោះ ។ យើងត្រូវដឹងថាចំណិតខែដែលលេចឡើងក្រោយខែដែលមាន ៣០ ថ្ងៃនៃប្រក្រតិទិនចន្ទគតិបានកន្លងផុតទៅនោះ ព្រោះគេមើលឃើញចំណិតខែនេះធំជាងហើយរះយូរជាងចំណិតខែដែលលេចឡើងក្រោយខែដែលមាន ២៩ ថ្ងៃ ។

គេកំណត់ថ្ងៃដំបូងរបស់ខែដូចតទៅ គឺ៖

១. បើអ្នកណាម្នាក់មើលឃើញខែដោយខ្លួនឯងផ្ទាល់ ។

២. បើអ្នកណាម្នាក់អះអាងបញ្ជាក់ថាខ្លួនបានមើលឃើញខែ ហើយសម្តីរបស់អ្នកនេះស្របតាមម្នាក់ទៀត ដូចអ្វីៗផ្សេងៗទៀតដែរដែលស្របតាមម្នាក់នេះ ។

៣. បើមានមនុស្សតែពីរនាក់បានអះអាងថាបានមើលឃើញខែ ថ្ងៃដំបូងរបស់ខែនឹងមិនត្រូវទទួលយកបានទេ ប្រសិនបើមនុស្សទាំងពីរនាក់នេះមិនស្របមតិគ្នាក្នុងការរៀបរាប់អំពីការមើលឃើញខែនោះ ។

៤. ចាប់ពីខ្មើតរបស់ខែស្ហ្មាក៉ុបានទៅ បើ ៣០ ថ្ងៃបានកន្លងទៅហើយ គេកំណត់ថ្ងៃ

ដំបូងរបស់ខែរ៉ម៉ាដូនបានហើយ ។ ចាប់ពីថ្ងៃទីមួយខែរ៉ម៉ាដូនទៅ បើ ៣០ ថ្ងៃបានកន្លងផុតទៅហើយ គេកំណត់ថ្ងៃដំបូងរបស់ខែស្វាវ៉ាល់បានហើយ ។

ទោះបីខែរះយ៉ាងខ្ពស់នៅលើមេឃ ឬ កម្រលិចក៏ដោយ វាមិនមែនជាភ័ស្តុតាងបញ្ជាក់ថាខែនេះបានលេចឡើងហើយកាលពីម្សិលមិញនោះទេ ។ ដូចគ្នាដែរ ប្រសិនបើខែបាំងឆត្រ (មានរង្វង់ពន្លឺមូលនៅជុំវិញខែ) មិនមានន័យថាខែថ្មីបានលេចឡើងហើយកាលពីយប់ម្សិលនោះទេ ។

**មេរៀនទី ៦**

# ស្ម៉ឡាត់ អាល់-កូស្ស៊រ(១)

**ស្ម៉ឡាត់ទាំង ១៧ រ៉ក់អាត់ត្រូវបង្រួញបែបណា**

មាន ១៧ រ៉ក់អាត់ក្នុងស្ម៉ឡាត់វ៉ាយ៊ីបប្រចាំថ្ងៃ គឺ៖

ហ្សាច់រ(២) ស៊ូស្ស៊រ(៤) អាស្ស៊រ(៤) ម៉ាក់រីប(៣) អ៊ីស្ម៉ាអ៊(៤) ។

ប៉ុន្តែ អ្នកធ្វើដំណើរនឹងបំពេញស្ម៉ឡាត់តែ ១១ រ៉ក់អាត់ទេ ។ ស្ម៉ឡាត់ហ្សាច់រ(២)និង ម៉ាក់រីប(៣) មិនផ្លាស់ប្តូរទេ តែស្ម៉ឡាត់ស៊ូស្ស៊រ(៤) អាស្ស៊រ(៤) និង អ៊ីស្ម៉ាអ៊(៤) សល់តែ ២ រ៉ក់អាត់ទេ ដែលតាមធម្មតាមាន ៤ រ៉ក់អាត់នោះ ។

ស៊ូណាត់ឲ្យអ្នកធ្វើដំណើរសូត្រ ៣០ ដងថា "ស៊ុបហ្ពាណុលឡ៍ហ្វ៊ី វ៉ាល់ ហ្ពាំឌូលិលឡាហ្វ៊ី វ៉ា ឡា អ៊ីឡាហ្វា អ៊ីលឡលឡ៍ហ្វ វ៉ល់ឡ៍ហ្វ អាក់បារ" ក្រោយស្ម៉ឡាត់នីមួយៗ ។ ស៊ូណាត់ធំឲ្យសូត្រឌូអាអ៊ក្រោយស្ម៉ឡាត់ស៊ូស្ស៊រ អាស្ស៊រ និង អ៊ីស្ម៉ាអ៊ ហើយឲ្យសូត្រស៊ីករខាងលើនេះ ៦០ ដែលតាមធម្មតាឲ្យសូត្រ ៣០ ដង ក្រោយស្ម៉ឡាត់ទាំងបីនេះ ។

**លក្ខខណ្ឌ**(១)

ដើម្បីបំពេញស្ម៉ឡាត់ អាល់-កូស្ស៊របាន អ្នកធ្វើដំណើរត្រូវមានលក្ខខណ្ឌ (ស្ម៉រ៉ាត់ شرط) ៧ ប្រការគឺ៖

១. ចម្ងាយផ្លូវ(ទៅ-មក)មិនត្រូវតិចជាង ៤៥ គីឡូម៉ែត្រទេ ។
២. អ្នកធ្វើដំណើរត្រូវនៅក្រៅព្រំដែនស្រុក ។
៣. មុនចេញដំណើរ អ្នកធ្វើដំណើរត្រូវនៀតយ៉ាងច្បាស់ថាចង់ធ្វើដំណើរយ៉ាងជិត

៩៥ គីឡូម៉ែត្រ (ទៅ-មក) ឬ លើសពីនោះ ។

៤. ការធ្វើដំណើរមិនមែនជាការធ្វើដំណើរដែលត្រូវហាម ឬ ធ្វើក្នុងបំណងទុច្ចរិត (ហ្ារ៉ាំ) ទេ ។

៥. បំណង (គឺនៀត) ស្នាក់នៅត្រូវតិចជាង ១០ ថ្ងៃ ។

៦. ទីដៅមិនមែនជាកន្លែងដែលអ្នកធ្វើដំណើររស់នៅទេ-វ៉ាតាន់ ។

៧. ការធ្វើដំណើរដែលមិនមែននៅក្នុងចម្ងាយផ្លូវដូចសព្វដង ដែលអ្នកធ្វើដំណើរតែងតែទៅមកក្នុងការប្រកបមុខរបរខ្លួននោះទេ ។

**លក្ខខណ្ឌ(២)**

**១. ចម្ងាយផ្លូវ(ទៅ-មក)មិនត្រូវតិចជាង ៩៥ គីឡូម៉ែត្រទេ ។**

ក) បើចម្ងាយសរុបរបស់ការធ្វើដំណើរទៅនិងមកមាន ៩៥ គីឡូម៉ែត្រ អ្នកធ្វើដំណើរត្រូវបង្រួញស្វ៍ឡាត់ ទោះបីការដើរផ្លូវ (ទៅ ឬ មក) នោះតិចជាង ២២ គីឡូម៉ែត្រក៏ដោយ ។ ដូច្នេះ បើដំណើរផ្លូវទៅមាន ១៩ គីឡូម៉ែត្រ ឯដំណើរផ្លូវមកវិញមាន ២៦ គីឡូម៉ែត្រ ឬ ផ្ទុយគ្នា អ្នកធ្វើដំណើរត្រូវបង្រួញស្វ៍ឡាត់ (ពោលគឺ ២ រ៉ក់អាត់ ដែលតាមធម្មតា ៤ រ៉ក់អាត់) ។

ខ) បើអ្នកអាឌីល (គឺអ្នកត្រឹមត្រូវ) ឬ អ្នកដែលគេទុកចិត្តប្រាប់អ្នកធ្វើដំណើរថាដំណើរផ្លូវរបស់គាត់នោះសរុបមានចម្ងាយស្មើនឹង ៩៥ គីឡូម៉ែត្រ អ្នកដំណើរត្រូវបង្រួញស្វ៍ឡាត់ បើខ្លួនគិតថាស័ក្តិសមមែន ។

គ) បើអ្នកណាមិនប្រាកដអំពីចម្ងាយ (៩៥ គ.ម) ទេ អ្នកនោះត្រូវបំពេញស្វ៍ឡាត់ពេញ (មិនបង្រួញ) ។

ឃ) បើអ្នកដំណើរជឿជាក់ថាបានធ្វើដំណើរបាន ៩៥ គ.ម. ហើយក្នុងការដើរផ្លូវនេះអ្នកនោះនឹងបំពេញស្វ៍ឡាត់អាល់-ក្វស្វ៍រ ។ តែបើដឹងនៅពេលក្រោយថាបានខុសហើយ អ្នកនោះត្រូវបំពេញស្វ៍ឡាត់ពេញ (មិនបង្រួញ) តែដោយនៀតថាក៏វ៉ដ្ឋ៍ ។

ង) ដូចគ្នាដែរ បើអ្នកដំណើរណាជឿជាក់ថាខ្លួនមិនបានដើរផ្លូវគ្រប់ ៨៥ គ.ម. ទេ បន្ទាប់មកបានដឹងថាខ្លួនខុសហើយ អ្នកនោះត្រូវបំពេញស្ វឡាត់អាល់-កូស្ស័រ ។

ច) បើមានផ្លូវពីរទៅកាន់កន្លែងតែមួយ ផ្លូវមួយមានចម្ងាយ ៨៥ គ.ម. ឯផ្លូវមួយទៀតទេ អ្នកដំណើរដែលដើរផ្លូវឆ្ងាយ ៨៥ គ.ម. ត្រូវបំពេញស្ វឡាត់ អាល់-កូស្ស័រ ឯអ្នកដំណើរផ្លូវដែលមានចម្ងាយតិចជាង ៨៥ គ.ម. ត្រូវបំពេញស្ វឡាត់ពេញ (មិនបង្រួញទេ) ។

ឆ) បើអ្នកដំណើរ ក្នុងពេលដើរផ្លូវ កាត់តាមស្រុកដែលខ្លួនរស់នៅ មុននឹងធ្វើដំណើរ ៨៥ គ.ម. នោះ ចម្ងាយសរុបត្រូវរាប់ចាប់ពីកន្លែងក្រោយបង្អស់ដែលអ្នកនោះបានដើរកាត់ ពោលគឺ ស្រុកដែលអ្នកនោះរស់នៅ ។

ជ) ការរាប់ចម្ងាយផ្លូវ ត្រូវប្រព្រឹត្តទៅចាប់ពីចំណុចដែលអ្នកដំណើរបានឆ្លងកាត់ព្រំដែនក្រៅរបស់ស្រុកដែលខ្លួនរស់នៅ ។

## ២. អ្នកធ្វើដំណើរត្រូវនៅក្រៅព្រំដែនស្រុក

ក) **ហាដ់ អល់-តារ៉ក់ឃុស** គឺកន្លែងដែលជាចុងបំផុតរបស់ព្រំប្រទល់ស្រុក ។ គេអាចសម្គាល់កន្លែងនេះបានដោយវិធីដូចតទៅ គឺ៖

១) កន្លែងដែលបន្ទាយរបស់ស្រុកត្រូវសាងសង់ ។

២) កន្លែងដែលរាជការទីក្រុងបានដាក់ស្លាកសំគាល់ផ្លូវចេញ និងផ្លូវចូលរបស់ស្រុក ។

ខ) បើអ្នកដំណើរមិនប្រាកដថាបានដើរឆ្លង ហាដ់ អាល់-តារ៉ក់ឃុស ហើយឬទេ ឲ្យបំពេញស្ វឡាត់ពេញ (មិនបង្រួញ) ។ ដូចគ្នាដែរ បើអ្នកដំណើរមិនប្រាកដថាបានដើរឆ្លង ហាដ់ អាល់-តារ៉ក់ឃុស ហើយឬទេ ពេលត្រឡប់មកកាន់ទីលំនៅវិញនោះ ឲ្យបំពេញស្ វឡាត់ អាល់-កូស្ស័រ ។

**៣. មុនចេញដំណើរ អ្នកដំណើរត្រូវនៀតយ៉ាងច្បាស់ថាចង់ធ្វើដំណើរយ៉ាងជិត ៤៥ គីឡូម៉ែត្រ (ទៅ-មក) ឬ លើសពីនោះ ។**

ក) បើអ្នកណាទៅកាន់កន្លែងមួយដែលមានចម្ងាយតិចជាង ៤៥ គ.ម. ឧទាហរណ៍ ពេលដើរបាន ១៩ គ.ម. សម្រេចចិត្តដើរបន្តដល់ទៅ ២៩ គ.ម. អ្នកនោះត្រូវបំពេញស្ទ្រឡាត់ពេញ (មិនបង្រួញ) ព្រោះអ្នកនោះមិនបានប៉ង (គឺនៀត) តាំងពីដើមមកថាចង់ដើរផ្លូវ ៤៥ គ.ម.នោះទេ ។

ខ) អ្នកណាមិនស្គាល់ចម្ងាយផ្លូវសរុបទេ (ឧទាហរណ៍ អ្នកនោះដើររករបស់ដែលបានបាត់ ឬដេញតាមចោរ...) អ្នកនោះត្រូវបំពេញស្ទ្រឡាត់ពេញ (មិនបង្រួញ) ។ ក៏ប៉ុន្តែ បើអ្នកនោះស្គាល់ចម្ងាយផ្លូវត្រឡប់វិញ ហើយចម្ងាយផ្លូវនោះមាន ៤៥ គ.ម. អ្នកនោះត្រូវបំពេញស្ទ្រឡាត់អាល់-ក្វស្រ៍ ។

គ) បំណាង (គឺនៀត) ត្រូវតែម៉ឺងម៉ាត់ ។ អ្នកដំណើរមិនត្រូវប្តូរបំណាងក្នុងពេលកំពុងធ្វើដំណើរទេ ហើយក៏មិនត្រូវសង្ស័យអំពីការបន្តដំណើរទេ ។ ក្នុងករណីចុងក្រោយនេះ អ្នកនោះត្រូវរាប់ចម្ងាយផ្លូវចាប់ពីកន្លែងដែលខ្លួនបាននៀតសាថ្មីនេះ បើមានចម្ងាយ ៤៥ គ.ម. អ្នកនោះនឹងបំពេញស្ទ្រឡាត់អាល់-ក្វស្រ៍ ។

**មេរៀនទី ៧**

# ស្ហ៏ឡាត់ អាល់-ក្វស្ហ៏រ(២)

**៤. ការធ្វើដំណើរមិនមែនជាការធ្វើដំណើរដែលត្រូវហាម ឬ ក្នុងបំណងទុច្ចរិត (ហ្ការ៉ាំ) ទេ ។**

ក) បើអ្នកណាធ្វើដំណើរដើម្បីប្រព្រឹត្តអំពើ ដែលច្បាប់អ៊ីស្លាមស្ហារីអ៊ុស្ហ៍ហាម (ឧទាហរណ៍ អ្នកណាធ្វើដំណើរក្នុងបំណងទៅលួចគេ ទៅចូលរួមក្នុងពិធីកំសាន្តដែលមានការច្រៀង រាំ...) ការធ្វើដំណើរនេះត្រូវចាត់ទុកថាក្នុងគោលបំណងហ្ការ៉ាំ ។ ក្នុងករណីនេះ អ្នកដំណើរត្រូវបំពេញស្ហ៏ឡាត់ពេញ (មិនបង្រួញទេ) ។ ប្រើច្បាប់នេះដែរ ក្នុងករណីដែលការធ្វើដំណើរត្រូវហាមតែម្តង ។ ឧទាហរណ៍ ក្មេងធ្វើដំណើរដោយមិនស្តាប់បម្រាមឪពុកម្តាយ ។ក៏ប៉ុន្តែ បើជាដំណើរវ៉ាយ៉ិប (ឧទាហរណ៍ ទៅបំពេញពិធីហ្កាច្ច) ឲ្យបំពេញស្ហ៏ឡាត់បង្រួញ (ស្ហ៏ឡាត់ អាល់-ក្វស្ហ៏រ) ។

ខ) ដំណើរដែលមិនវ៉ាយ៉ិប ហើយដែលបណ្តាលឲ្យឪពុកម្តាយមានសេចក្តីលំបាក ជាដំណើរហ្ការ៉ាំ ។ អាស្រ័យហេតុនេះ ត្រូវបំពេញស្ហ៏ឡាត់ពេញ (មិនបង្រួញ) នៅពេលធ្វើដំណើរបែបនេះ ។

គ) បើអ្នកណាមិនធ្វើដំណើរក្នុងគោលបំណងហ្ការ៉ាំទេ ហើយការធ្វើដំណើរនេះមិនត្រូវហាមទេ អ្នកនោះអាចបំពេញស្ហ៏ឡាត់ អាល់-ក្វស្ហ៏របាន ទោះបីអ្នកនោះធ្វើអំពើបាបក្នុងពេលធ្វើដំណើរនេះក៏ដោយ (ឧទាហរណ៍ ផឹកស្រា និយាយដើមគេ...) ។

**៥. បំណង (នៀត) ស្នាក់នៅត្រូវតិចជាង ១០ ថ្ងៃ ។**

ក) បើអ្នកណាចង់ស្នាក់នៅកន្លែងណាមួយ ១០ ថ្ងៃ ឬគិតថាប្រហែលនឹងស្នាក់នៅ ១០ ថ្ងៃ អ្នកនោះត្រូវបំពេញស្ហ៏ឡាត់ពេញ (មិនបង្រួញ) ។

ខ) រយៈពេល ១០ ថ្ងៃគឺមានដូចតទៅ គឺៈ
១) យ៉ាងហោចណាស់ ចាប់ពីថ្ងៃរះនៃថ្ងៃទីមួយរហូតដល់ថ្ងៃលិចនៃថ្ងៃទី ១០ ។
២) ឬយ៉ាងហោចណាស់ ចាប់ពីពេលស៊ុស្ហ៍នៃថ្ងៃទីមួយរហូតដល់ពេលស៊ុស្ហ៍នៃថ្ងៃ ទី ១១ ។

គ) ប្រសិនបើអ្នកណាមិនបាននៀតយ៉ាងម៉ឹងម៉ាត់ទេថានឹងស្នាក់នៅ ១០ ថ្ងៃនៅកន្លែងណាមួយ (ឧទាហរណ៍ អ្នកនោះនឹងស្នាក់នៅបើមានកន្លែងណាមួយដែលខ្លួនពេញចិត្ត) អ្នកនោះត្រូវបំពេញស្វ៍ឡាត៌ពេញ (មិនបង្រួញ) ។

ឃ) បើអ្នកដំណើរប៉ងស្នាក់នៅតិចជាង ១០ ថ្ងៃនៅកន្លែងណាមួយ ហើយស្រាប់តែផ្លាស់ប្តូរដោយចៃដន់ ត្រូវស្នាក់នៅលើសពី ១០ ថ្ងៃវិញ (ឧទាហរណ៍ អ្នកនោះមិនទាន់បានទទួលចម្លើយឲ្យចេញដំណើរបានពីទីភ្នាក់ងារគមនាការ) អ្នកនោះអាចបន្តបំពេញស្វ៍ឡាត៌អាល់-កូស្វ៍របានដរាបណាអ្នកនោះស្ថិតនៅក្នុងភាពមិនទៀងបែបនេះ ។ ក៏ប៉ុន្តែ ក្រោយពី ៣០ ថ្ងៃ អ្នកនោះត្រូវបំពេញស្វ៍ឡាត៌ពេញវិញ ទោះបីប្រាកដថានឹងបានចេញដំណើរមួយថ្ងៃទៀតក៏ដោយ ។

**៦. ទិសដៅមិនមែនជាកន្លែងដែលអ្នកដំណើររស់នៅទេ-វ៉ាតាន់ ។**

ក) កន្លែងដែលអ្នកណាម្នាក់ជ្រើសរើសជាកន្លែងសម្រាប់រស់នៅ កន្លែងដែលគេចង់រស់នៅរហូតមួយជីវិត ហៅថា **វ៉ាតាន់** ពោលគឺ ស្រុកដែលអ្នកនោះរស់នៅ ។ ទោះបីអ្នកនោះកើតនៅក្នុងស្រុកនោះក៏ដោយ ទោះបីជាស្រុករបស់ឪពុកម្តាយអ្នកនោះក៏ដោយ មិនមែនជាបញ្ហាក្នុងការកំណត់ជាវ៉ាតាន់ទេ ។

ខ) បើអ្នកណាសម្រេចចិត្តស្នាក់នៅកន្លែងណាមួយជាបណ្តោះអាសន្ន មួយរយៈសិន ហើយផ្លាស់ទៅនៅកន្លែងមួយទៀត កន្លែងរស់នៅនេះមិនមែនជាវ៉ាតាន់របស់អ្នកនោះទេ ។

គ) បើអ្នកណាមានកន្លែងរស់នៅពីរ (ឧទាហរណ៍ រស់នៅ ៦ ខែកន្លែងមួយ ហើយរស់នៅ ៦ ខែកន្លែងមួយទៀត) កន្លែងទាំងពីរនេះជាវ៉ាតាន់របស់អ្នកនោះ ។ ការពិត បើមានកន្លែងរស់នៅច្រើន ចាត់ទុកកន្លែងអស់នេះជាវ៉ាតាន់របស់អ្នកនោះ ។

ឃ) បើអ្នកណាស្នាក់នៅតិចជាង ១០ ថ្ងៃកន្លែងណាមួយដែលធ្លាប់ជាវ៉ាតាន់របស់ខ្លួនកាលពីមុន អ្នកនោះត្រូវបំពេញស្វ៍ឡាត់បង្រួញ (កូស្វ៉រ៍) ទោះបីអ្នកនោះមិនទាន់រកបានកន្លែងរស់នៅផ្សេងទៀតក៏ដោយ ។

## ៧. ការធ្វើដំណើរដែលមិនមែននៅក្នុងចម្ងាយផ្លូវដូចសព្វដង ដែលអ្នកដំណើរតែងតែទៅមកក្នុងការប្រកបមុខរបរខ្លួននោះទេ ។

ក) មុខរបររបស់អ្នកដំណើរមិនតម្រូវឲ្យអ្នកនោះធ្វើដំណើររហូតទេ (ឧទាហរណ៍ អ្នកបើកបរ អ្នកប្រកបមុខរបរលើរទេះភ្លើង យន្តហោះ នាវា...) ។ ដូចគ្នាដែរ បើអ្នកណាធ្វើដំណើរឆ្ងាយក្នុងការប្រកបមុខរបររៀងរាល់ថ្ងៃ ឬ យ៉ាងញឹកញយ អ្នកនោះត្រូវបំពេញស្វ៍ឡាត់ពេញ (មិនបង្រួញ) ។

ខ) ការធ្វើដំណើរមិនត្រូវឲ្យដូចការធ្វើដំណើររបស់ចរកជន ដែលដើរចច្រប់រៀងរហូតពីកន្លែងមួយទៅកន្លែងមួយនោះទេ ដើម្បីស្វែងរកទឹកឬស្មៅឲ្យសត្វពួកគេ ។ ពួកគេឈប់ពេលណាពួកគេពេញចិត្តនឹងកន្លែងណាមួយ បន្ទាប់ពីនោះចាកចេញទៅកាន់ទិសដៅមួយទៀត ។ ប្រជារាស្ត្រនេះត្រូវបំពេញស្វ៍ឡាត់ពេញ (មិនបង្រួញ) ។

គ) ពេលណាអ្នកណា ដូចជាអ្នកបើកបរ អ្នកបើកយន្តហោះ អ្នកបើកនាវា និងចរកជន ជាដើម ធ្វើដំណើរដែលមិនពាក់ព័ន្ធនឹងមុខរបររបស់ខ្លួនទេ ពេលនោះអ្នកទាំងនោះអាចបំពេញស្វ៍ឡាត់ អាល់-កូស្វ៉រ៍ បាន បើសមស្របតាមលក្ខខណ្ឌទាំងអស់ (ឧទាហរណ៍ បើជនទាំងនេះធ្វើដំណើរក្នុងគោលបំណងបំពេញពិធីហ្វាច្ច ឬ ស៊ីយ៉ារ៉ត់) ។ ដូចគ្នាដែរ អ្នកបើកបរដែលដឹកជញ្ជូនទំនិញពីកន្លែងមួយទៅកាន់កន្លែងមួយទៀត ធ្វើដំណើរដើម្បីទៅសម្រាកការងារ ២

ថ្ងៃងស្រុកឆ្ងាយមួយ ជាឧទាហរណ៍ អ្នកនោះត្រូវបំពេញស្ម៏ឡាត់ អាល់-កូស្វ៍រ ។

## នៅក្នុងបូនីយដ្ឋាន

អ្នកដំណើរអាចជ្រើសរើសយកស្ម៏ឡាត់ពេញ ឬ ស្ម៏ឡាត់បង្រួញនៅក្នុងបូជនីយដ្ឋានខាងក្រោមនេះគឺ៖

១. ម៉ាស់យ៊ីឌុល-ហ្ការ៉ម (កាក់បាស់) និងក្នុងស្រុកម៉ាក់កាស់ទាំងមូល ។
២. ម៉ាស់យ៊ីដ្ទ ណាបាវី និងស្រុកម៉ាឌីណាស់ទាំងមូល (ម៉ាស់យ៊ីដ្ទណាប៊ី មូហ្កាំម៉ាដ់ ﷺ) ។
៣. ម៉ាស់យ៊ីដ្ទ គូហ្វាស់ ។
៤. ហ្ការ៉ម អ៊ីម៉ាំ ហ៊្វូសៃន៍ صلوات الله عليه والسلام កន្លែងបញ្ចុះព្រះបរមសពព្រះអង្គ صلوات الله عليه والسلام ។

## មេរៀនទី ៨

# ស្វ៍ឡាត់ អាល់-កូស្វ៍រ(៣)

**សេចក្ដីបញ្ជាក់នានាពាក់ព័ន្ធនឹងស្វ៍ឡាត់ អាល់-កូស្វ៍រ**

១. បើអ្នកណាដឹងថាត្រូវបំពេញស្វ៍ឡាត់អាល់-កូស្វ៍រ តែបានបំពេញស្វ៍ឡាត់ពេញដោយចេតនាជួសស្វ៍ឡាត់បង្រួញនោះ នៅក្នុងកន្លែងណាមួយផ្សេងពីកន្លែងដែលបានចែងខាងលើហើយ ស្វ៍ឡាត់អ្នកនោះត្រូវមោឃៈ។ ក៏ប៉ុន្តែបើអ្នកនោះភ្លេចថាត្រូវបំពេញស្វ៍ឡាត់បង្រួញ ហើយបានបំពេញស្វ៍ឡាត់ពេញ បន្ទាប់មកក៏បាននឹកឃើញវិញ ឲ្យអ្នកនោះបំពេញស្វ៍ឡាត់កុ៏ដ៏ ។

២. បើអ្នកដំណើរមិនដឹងថាត្រូវស្វ៍ឡាត់បង្រួញទេ ហើយក៏បានស្វ៍ឡាត់ពេញ ស្វ៍ឡាត់របស់អ្នកនោះត្រឹមត្រូវ ។

៣. បើអ្នកណាដឹងថាត្រូវបំពេញស្វ៍ឡាត់បង្រួញតែមិនស្គាល់លក្ខខណ្ឌ ហើយក៏បានស្វ៍ឡាត់ពេញ អ្នកនោះត្រូវស្វ៍ឡាត់សាជាថ្មីបើបានដឹងលក្ខខណ្ឌរបស់ស្វ៍ឡាត់បង្រួញមុននឹងដល់ពេលកុ៏ដ៏។ បើអ្នកនោះមិនស្វ៍ឡាត់សាថ្មីទេ អ្នកនោះត្រូវស្វ៍ឡាត់កុ៏ដ៏។ ក៏ប៉ុន្តែបើអ្នកនោះមិនស្គាល់លក្ខខណ្ឌរបស់ស្វ៍ឡាត់អាល់-កូស្វ៍រទេ ទាល់តែហួសពេលស្វ៍ឡាត់ អ្នកនោះមិនបាច់ស្វ៍ឡាត់សាថ្មីទេ ។

៤. បើអ្នកដំណើរមិនទាន់ស្វ៍ឡាត់មុនពេលស្វ៍ឡាត់ហួសទេ ហើយបានដល់ទីលំនៅឬកន្លែងដែលខ្លួនចង់ស្នាក់នៅតិចជាង ១០ ថ្ងៃនោះ អ្នកនោះត្រូវស្វ៍ឡាត់ពេញ ។

៥. បើអ្នកណា ដែលមិនមែនជាអ្នកដំណើរទេ មិនបានស្វ៍ឡាត់ភ្លាមៗក្នុងពេលវេលាទេ ហើយក៏បានធ្វើដំណើរ អ្នកនោះត្រូវស្វ៍ឡាត់បង្រួញក្នុងពេលធ្វើដំណើរ ។

៦. ប្រសិនបើស្ហ៏ឡាត់ស៊ុស្ហូរ៍ អ៊ាស្ហ៊ូរ៍ ឬ អ៊ីស្ហាអ៍ របស់អ្នកដំណើរបានផុតទៅជាក្ហ៏ដ្ហ៏ ហើយ អ្នកនោះនៅតែមិនទាន់បានបំពេញស្ហ៏ឡាត់ទាំងនេះទេ អ្នកនោះត្រូវស្ហ៏ឡាត់ក្ហ៏ដ្ហ៏បង្រួញ ទោះបីអ្នកនោះលែងធ្វើដំណើរហើយក៏ដោយ ។

៧. បើអ្នកណា ដែលមិនមែនជាអ្នកដំណើរទេ មិនស្ហ៏ឡាត់ស៊ុស្ហូរ៍ អ៊ាស្ហ៊ូរ៍ ឬ អ៊ីស្ហាអ៍ ទាន់ពេលទេ អ្នកនោះត្រូវស្ហ៏ឡាត់ពេញ ទោះបីស្ហ៏ឡាត់ក្ហ៏ដ្ហ៏ក៏ដោយ ក្នុងពេលដែលកំពុងធ្វើដំណើរ ។

## មេរៀនទី ៩

# តាយ៉ាំមុម(១)

**តើគេធ្វើតាយ៉ាំមុមនៅពេលណា ?**

### ១. បើអ្នកមិនមានទឹកដើម្បីយកទឹកវូឌូអ៊ូ ឬ គូស៊ូល (ឬ គុសល៍) ទេ

ក) អ្នកត្រូវព្យាយាមស្វែងរកទឹកក្នុងបរិវេណដែលអ្នករស់នៅ ។

ខ) បើអ្នកនៅសល់ពេលបន្តិចមុនស្វ៍ឡាត្ជូលដល់ពេលក៏ដ្ឋ៍ ហើយអ្នកស្គាល់កន្លែងមានទឹក អ្នកមិនអាចធ្វើតាយ៉ាំមុមបានទេ ។ ក៏ប៉ុន្តែបើអ្នកមិនប្រាកដថាមានទឹកនៅកន្លែងផ្សេង អ្នកអាចធ្វើតាយ៉ាំមុមបាន ។

គ) បើអ្នកគិតថាមិនអាចរកទឹកបានទេ ហើយអ្នកបានធ្វើតាយ៉ាំមុម តែបន្ទាប់ពីនោះអ្នករកទឹកបានមុនស្វ៍ឡាត្ជូលដល់ពេលក៏ដ្ឋ៍ ក្នុងករណីនេះ អ្នកត្រូវយកទឹកវូឌូអ៊ូជាមួយទឹកដែលរកបាននោះ ហើយបំពេញស្វ៍ឡាត្សាថ្មី ។

### ២. បើអ្នកមិនអាចរកទឹកបានដោយសារមូលហេតុផ្សេងៗ (វ័យជរា ខ្សោយ ខ្លាចចោរ ឬ សត្វសាហាវ) ឬ អ្នកមិនមានមធ្យោបាយយោងទឹកអណ្តូងបាន

ក) បើអ្នកត្រូវទិញរបស់របរដូចជាធុងទឹក ខ្សែ... ដើម្បីយោងទឹក ហើយអ្នករកសម្ភារៈទាំងនេះបាន មិនចាត់ទុកថាអ្នកគ្មានមធ្យោបាយនោះទេ ក្នុងការរកបាននូវរបស់ចាំបាច់នោះ ។

ខ) បើអ្នកនៅក្នុងស្ថានភាពចាំបាច់ត្រូវខ្ចីប្រាក់ដើម្បីទិញទឹក អ្នកត្រូវខ្ចីប្រាក់នោះបើអាចសងប្រាក់នោះវិញបាន ។ បើអ្នកគិតថាមិនអាចរកប្រាក់សងវិញបានទេ មិនមែនជាវ៉ាយ៉ិបត្រូវធ្វើបែបនេះទេ ។

គ) ប្រសិនបើត្រូវជីកអណ្តូងដើម្បីផ្តល់ទឹក អ្នកត្រូវតែធ្វើ ។

ឃ) ប្រសិនបើគេឲ្យទឹកអ្នកដោយមិនសូមអ្វីពីអ្នកទេ អ្នកត្រូវតែទទួលយកទឹក

នោះ ។

**៣. បើអ្នកមានទឹកតែអ្នកគិតថានឹងប្រើអស់ទឹកនោះពេលយកទឹកវូឌុអ៊ុំ ឬ គូស៊ូល ដូច្នេះអ្នកផ្សេង ឬសត្វអាចស្លាប់បានដោយសារអត់ទឹក**

អ្នកអាចធ្វើតាយ៉ាំមុមបានបើអ្នកគិតថាការខ្វះទឹកដោយសារវូឌុអ៊ុំ ឬ គូស៊ូល របស់អ្នកអាចធ្វើឲ្យអ្នកឈឺឬស្លាប់បាន ឬអាចធ្វើឲ្យអ្នកដែលនៅក្នុងបន្ទុកអ្នកឈឺឬស្លាប់បាន ឬអាចធ្វើឲ្យសត្វឬអ្នកឯទៀតស្លាប់បាន ។

**៤. បើអ្នកមានទឹកគ្រប់គ្រាន់សម្រាប់តែលាងប៉ែកខ្លួនអ្នក ឬសំលៀកបំពាក់ដែលណាយ៉ីស**

ដើម្បីបង្ការ អ្នកត្រូវធ្វើគូស៊ូល ឬ បោកសំលៀកបំពាក់ រួចហើយបំពេញស្វ៍ឡាត្តុំក្រោយពីបានធ្វើតាយ៉ាំមុម ។ ក៏ប៉ុន្តែ បើអ្នកមិនមានអ្វីមួយដើម្បីធ្វើតាយ៉ាំមុមទេ (ដីខ្សាច ដុំ ថ្ម...) អ្នកត្រូវប្រើទឹកដើម្បីធ្វើតែវូឌុអ៊ុំ ហើយទុកណាយ៉ីសនៅលើខ្លួនអ្នកឬលើសំលៀកបំពាក់អ្នក ។

**៥. បើអ្នកមិនមានពេលគ្រប់គ្រាន់ដើម្បីងូតទឹកគូស៊ូល ឬ យកទឹកវូឌុអ៊ុំទេ**

ក) បើអ្នកបង្អែបង្អង់ពេលដោយចេតនា ទាល់តែមិនមានពេលគ្រប់គ្រាន់ដើម្បីងូតទឹក គូស៊ូល យកទឹកវូឌុអ៊ុំ អ្នកប្រព្រឹត្តអំពើបាបមួយ តែស្វ៍ឡាត្តុំក្រោយពីបានធ្វើតាយ៉ាំមុមរួចនោះមិនមោឃៈទេ ។ ក៏ប៉ុន្តែ អ៊ិះហ្ទ៍ទីយ៉ាត្វ វ៉ាយ៉ីប ឲ្យបំពេញស្វ៍ឡាត្តុំនេះសាថ្មី ។

ខ) បើអ្នកសង្ស័យអំពីពេលដែលនៅសល់ដើម្បីបំពេញស្វ៍ឡាត្តុំ ក្រោយពីបានយកទឹក វូឌុអ៊ំ ឬ គូស៊ូល ក្នុងករណីនេះអ្នកត្រូវធ្វើតាយ៉ាំមុម ។

គ) បើអ្នកមិនយកទឹកវូឌុអ៊ុំទេដោយសារខ្វះពេល ហើយអ្នកដឹងថានឹងមិនមានទឹកគ្រប់គ្រាន់សម្រាប់ស្វ៍ឡាត្តុំនៅពេលខាងមុខទេ អ្នកត្រូវធ្វើតាយ៉ាំមុមម្តងទៀតទោះបីតាយ៉ាំមុមមុនមិនទាន់ដាច់ទេក៏ដោយ ។

ឃ) បើអ្នកគិតថា បើយកទឹកវ្ញខ្ញុំអ៊ុំ ឬ គ្លូស្វូល អ្នកបានត្រឹមតែបំពេញស្វ៍ឡាត់វ៉ាឃ្ល៊ីប ទេ ក្នុងករណីនេះអ្នកត្រូវតែយកទឹកវ្ញខ្ញុំអ៊ុំ ឬ គ្លូស្វូលនេះ ហើយកុំបំពេញស្វ៍ឡាត់ស្វណាត់ ។

## ៦. បើខ្លាចថាជីវិតអ្នកនឹងមានគ្រោះថ្នាក់ ឬ អ្នកនឹងមានជម្ងឺណាមួយ ឬ ជម្ងឺអ្នកនឹងមានអាការដុនដាបខ្លាំងឡើង

ក) អ្នកត្រូវធ្វើតាយ៉ាំមុម ឬ ពុំនោះទេអ្នកប្រើទឹកក្តៅជាជំនួស ។

ខ) មិនចាំបាច់ឲ្យប្រាកដថាទឹកនឹងផ្តល់គ្រោះថ្នាក់ដល់អ្នកនោះទេ ទោះបីអ្នកមានអារម្មណ៍ថាទឹកនោះអាចឆ្លងរោគមកអ្នក ក្នុងករណីនេះអ្នកអាចធ្វើតាយ៉ាំមុមបាន ។

គ) អាចធ្វើតាយ៉ាំមុមបានបើអ្នកមានជម្ងឺលើភ្នែក ហើយទឹកអាចធ្វើឲ្យភ្នែកនោះមានគ្រោះថ្នាក់បាន ។

ឃ) បើអ្នកធ្វើតាយ៉ាំមុមព្រោះអ្នកគិតថាទឹកមិនស្អាត ក្រោយមកអ្នកដឹងថាទឹកនោះស្អាត ក្នុងករណីរនេះ បើអ្នកមិនទាន់បានបំពេញស្វ៍ឡាត់ទេ អ្នកត្រូវតែយកទឹកវ្ញខ្ញុំអ៊ុំ ។ បើអ្នកបានបំពេញស្វ៍ឡាត់រួចហើយ ហើយមិនទាន់ហួសពេល ចូលដល់ពេលក៏ដ្ឋ៍ទេ អ៊ិះហ្វ៊ាទីយ៉ាត់ វ៉ាឃ្ល៊ីប ឲ្យយកទឹកវ្ញខ្ញុំអ៊ុំ ហើយបំពេញស្វ៍ឡាត់សាថ្មី ។ ក៏ប៉ុន្តែបើហួសពេល ចូលដល់ពេលក៏ដ្ឋ៍ហើយ អ្នកមិនត្រូវបំពេញស្វ៍ឡាត់សាថ្មីទេ ។

## ៧. បើអ្នកមានទឹកកុស់ប៊ី

បើទឹកដែលបានមកនោះ ឬ អ្វីដែលប្រើសម្រាប់ដាក់ទឹកនោះ កុស់ប៊ី (គឺលួចគេមក) អ្នកត្រូវធ្វើតាយ៉ាំមុម វាល្អជាងប្រើទឹកនោះសម្រាប់យកទឹកវ្ញខ្ញុំអ៊ុំ ឬ គ្លូស្វូល ។

**មេរៀនទី ១០**

# តាយ៉ាំមុម(២)

**អាចធ្វើតាយ៉ាំមុមបានលើ ៖**

ក) **ដី**

បើអាចរកដីបាន អ៊ិះហ្វ៍ទីយ៉ាត់ វ៉ាយ៉ីប ឲ្យធ្វើតាយ៉ាំមុមលើដីតែមួយមុខគត់ ។

ខ) **ដីខ្សាច់ ឬ ដីឥដ្ឋ**

បើអ្នករកដីមិនបានទេ អាចប្រើដីខ្សាច់ ឬ ពំនូកដីឥដ្ឋបាន ។

គ) **ថ្ម**

បើរកវត្ថុទាំងបីខាងលើនេះមិនបានទេ អ្នកអាចប្រើដុំថ្មបាន ។ អ្នកមិនអាចធ្វើតាយ៉ាំមុមលើថ្មរ៉ែបានទេ (ឧទាហរណ៍ ថ្មថ្លើមអណ្ដើក - អាគ្នីក្ញ) ។

ឃ) **ផង់ធូលី ឬ ដីទទឹក**

បើអ្នករកដី ដីខ្សាច់ ដីឥដ្ឋ ដុំថ្ម មិនបានទេ អ្នកអាចប្រើផង់ធូលីនៅលើផ្ទៃព្រំ ឬ លើសំលៀកបំពាក់បាន ។ បើរកមិនបានទេ អ្នកអាចប្រើដីទទឹកបាន ។

ង) **ព្រិល ឬ ទឹកកក**

បើអ្នករកព្រិល ឬ ទឹកកកបាន យកវាមករំលាយ ហើយយកទឹកវូឌុអ៊្ ឬ គូស៊្វល ជាមួយទឹកនេះ ។ បើអ្នកមិនអាចរំលាយវាបានទេ អាចធ្វើតាយ៉ាំលើព្រិល ឬ ទឹកកកបាន ។

ច) **ជញ្ជាំងដែលលាយដី**

បើមានជញ្ជាំងធ្វើអំពីដី អ៊ិះហ្វ៍ទីយ៉ាត់ វ៉ាយ៉ីប ឲ្យធ្វើតាយ៉ាំមុមលើជញ្ជាំងនេះល្អ

ជាងលើដីទទឹក ឬ ដីឥដ្ឋ ។

វត្ថុដែលអ្នកធ្វើតាយ៉ាំមុមលើនោះត្រូវតែបរិសុទ្ធ មិនត្រូវលួចគេមកទេ (យកមកដោយគ្មានការអនុញ្ញាតពីម្ចាស់វា) ឬ មានដើមកំណើតមកពីការលួចគេតៗមក ។ មិនត្រូវ កុស្ស៉ូប៊ី(غصب)ទេ ហើយក៏មិនត្រូវបានមកពីកន្លែងកុស្ស៉ូប៊ីទេដែរ ។ បើមិនស្របតាមលក្ខខណ្ឌទេ តាយ៉ាំមុមត្រូវមោឃៈ ។

វត្ថុដែលគេធ្វើតាយ៉ាំមុមលើនោះត្រូវជិតជាប់ដៃពេលគេចាប់វា ហើយក្រោយពីបានដដុសដៃទាំងពីរហើយក្រោយពីបានរលាស់ដៃទាំងពីរនេះ វត្ថុនោះត្រូវធ្លាក់មកលើដី ។

បើមិនស្របតាមលក្ខខណ្ឌខាងលើនេះទេ អ៊ិះហ្វ៉ាទីយ៉ាត់ វ៉ាយ៉ិប ឲ្យបំពេញស្វ៊ូឡាត់ដោយមិនមានតាយ៉ាំមុម ហើយវ៉ាយ៉ិបឲ្យបំពេញស្វ៊ូឡាត់សាថ្មីពេលមានទឹក (សម្រាប់ គូស្ស៊ុល ឬ វូឌូអ៊្) ឬពេលមានវត្ថុផ្សេងទៀតសម្រាប់ធ្វើតាយ៉ាំមុម ។

## វិធីធ្វើតាយ៉ាំមុម

ក) នៀតថា៖ "ខ្ញុំធ្វើតាយ៉ាំមុម [ឲ្យមូលហេតុ] វ៉ាយ៉ិប គូរបាតាន់ អ៊ីលឡុលឡោះហ្វ៍ ។"

ខ) យកបាតដៃទាំងពីរទះលើវត្ថុដែលធ្វើតាយ៉ាំមុមលើ (ឧទាហរណ៍ ដី...) ។

គ) យកបាតដៃទាំងពីរនេះមកដាក់លើជើងសក់ លើថ្ងាស ហើយអូសមកខាងក្រោមលុះដល់ចុងច្រមុះ ។

ឃ) យកបាត់ដៃឆ្វេងជូតលើខ្នងដៃស្តាំពេញ ។

ង) យកបាត់ដៃស្តាំជូតលើខ្នងដៃឆ្វេងពេញ ។

អ៊ិះហ្ក៍ទីយ៉ាត្ង់ មុសតាហ្រាប់ ឲ្យធ្វើតាយ៉ាំមុមតាមវិធីដូចតទៅ គឺ៖

១. នៀត ។

២. យកបាតដៃទាំងពីរទទះលើដី ។

៣. ជូតផ្ទៃមុខចាប់ពីថ្ងាសមកដល់ចុងច្រមុះ ។

៤. ជូតខ្នងដៃទាំងពីរ ។ ខ្នងដៃស្តាំមុនខ្នងដៃឆ្វេង ។

៥. យកបាតដៃទាំងពីរទទះលើដីម្តងទៀត ។

៦. ជូតខ្នងដៃទាំងពីរម្តងទៀត ។

## ច្បាប់តាយ៉ាំមុមផ្សេងៗទៀត

១. ពេលនៀតអ្នកត្រូវបញ្ជាក់ថាអ្នកធ្វើតាយ៉ាំមុម មិនមែនធ្វើវូឌូអ៍ឬគូស្ល៍ទេ ។

២. ក្នុងពេលដែលអ្នកធ្វើតាយ៉ាំមុម ត្រូវយកចេញនូវវត្ថុផ្សេងៗដែលអាចជាឧបសគ្គ ដូចជាចិញ្ចៀនជាដើម ។

៣. បើអ្នកមានក្រណាត់រុំរបួសលើថ្ងាស ឬលើខ្នងដៃ ដែលមិនអាចយកចេញបាន អាចធ្វើពីលើក្រណាត់រុំនោះបាន ។

៤. បើអ្នកមានក្រណាត់រុំលើបាតដៃដែលមិនអាចយកចេញបាន ចូរអ្នកយកដៃទៅទទះលើវត្ថុដែលយកមកធ្វើតាយ៉ាំមុមនោះ ហើយជូតតាមរបៀបធម្មតារបស់តាយ៉ាំមុម ។

៥. បើអ្នកមិនអាចធ្វើតាយ៉ាំមុមដោយខ្លួនឯងបានទេ អ្នកអាចរកគេជួយបាន ។ បុគ្គលដែល អ្នកសូមឲ្យជួយអ្នកនោះត្រូវជួយអ្នកធ្វើតាយ៉ាំមុមជាមួយដៃរបស់អ្នកផ្ទាល់ ។ បើមិនអាចធ្វើទៅបានទេ បុគ្គលនោះត្រូវប្រើដៃរបស់ខ្លួនឯង (ដៃរបស់បុគ្គលនោះ) ។

៦. អ្វីដែលធ្វើឲ្យវូឌូអ៍ ឬ គូស្ល៍លបាទិ្ទល(២៤) ធ្វើឲ្យតាយ៉ាំមុមបាទិ្ទលដែរ ។

**មេរៀនទី ១១**

# ស្វ៊ឡាត់ អាល់-អាយ៉ាត់ (صلاة الآيات)

**មូលហេតុដែលត្រូវបំពេញស្វ៊ឡាត់ អាល់-អាយ៉ាត់**

ស្វ៊ឡាត់ អាល់-អាយ៉ាត់ជាវ៉ាយុីបពេលណាព្រឹត្តិការណ៍ណាមួយខាងក្រោមនេះកើតឡើង គឺ៖

១. ថ្ងៃគ្រាស និង ខែគ្រាស (បាំងពន្លឺថ្ងៃ និង បាំងពន្លឺខែ) ។ ទោះបីបាំងថ្ងៃ ឬ បាំងខែតែបន្តិចដែលមិនធ្វើឲ្យខ្លាចក៏ដោយ ។

២. រញ្ជួយដី ។ ទោះបីមិនធ្វើឲ្យខ្លាចក៏ដោយ ។

៣. គ្រោះថ្នាក់ធម្មជាតិមួយណាក៏ដោយដែលបណ្តាលឲ្យខ្លាច ។ ឧទាហរណ៍៖ ខ្យល់ព្យុះ ព្យុះដែលបណ្តាលឲ្យខូចខាត... ក្នុងព្រឹត្តិការណ៍ទាំងនេះ ការភ័យរន្ធត់ជាលក្ខខណ្ឌចំបងរបស់ស្វ៊ឡាត់ ។ លក្ខណវិនិច្ឆ័យគឺសេចក្តីភ័យរន្ធត់ដែលមនុស្សភាគច្រើនទទួលអារម្មណ៍ ។ ក៏ប៉ុន្តែព្រឹត្តិការណ៍ណាមួយដែលមិនបណ្តាលឲ្យខ្លាចឬបណ្តាលឲ្យតែមនុស្សពីរបីនាក់ខ្លាចប៉ុណ្ណោះ មិនត្រូវចាត់ទុកជាលក្ខខណ្ឌដែលធ្វើឲ្យស្វ៊ឡាត់ទៅជាចាំបាច់ទេ ។

## ពេលដែលគេត្រូវបំពេញស្វ៊ឡាត់ អាល់-អាយ៉ាត់

ក្នុងពេលគ្រាសថ្ងៃ ឬ គ្រាសខែ អាចបំពេញស្វ៊ឡាត់បាន នៅពេលណាក៏បាន ក្នុងចន្លោះពេលដែលថ្ងៃ ឬ ខែចាប់ផ្តើមគ្រាស (គឺបាំងពន្លឺ) និងពេលដែលថ្ងៃ ខែឈប់គ្រាស ។ បើមិនបានស្វ៊ឡាត់ក្នុងពេលនេះទេ ត្រូវឆាប់ស្វ៊ឡាត់ក៏ដ្ហ៍ ។

អ្នកណាមិនដឹងថាមានថ្ងៃឬខែគ្រាសទេ ហើយបានដឹងពេលផុតគ្រាសហើយ អ្នកនោះត្រូវស្វ៊ឡាត់ក៏ដ្ហ៍ បើថ្ងៃឬខែគ្រាសនោះជាគ្រាសទាំងអស់តែម្តង ។ ក៏ប៉ុន្តែ បើជាថ្ងៃឬខែគ្រាសតែបន្តិច (ពោលគឺ មិនពេញ) មិនចាំបាច់បំពេញស្វ៊ឡាត់ក៏ដ្ហ៍ទេ ។

ពាក់ព័ន្ធនឹងព្រឹត្តិការណ៍ធម្មជាតិ ត្រូវបំពេញស្ឡ៉ាត់ អាល់-អាយ៉ាត់ភ្លាម ក្រោយពីភ័យវិបត្តិបានកន្លងផុតទៅ ។ អ្នកណាមិនស្ឡ៉ាត់ភ្លាមៗទេ អ្នកនោះធ្វើអំពើបាប (គូណាស់) ។ ក៏ប៉ុន្តែអ្នកនោះត្រូវបំពេញស្ឡ៉ាត់ តែផ្ទុយពីករណីថ្ងៃឬខែគ្រាស អ្នកនោះមិនបំពេញស្ឡ៉ាត់ដោយនៀតថា អាដាអ៊្(اداء) ឬ ក៏ដ្ធនោះទេ ។

## វិធីបំពេញស្ឡ៉ាត់ អាល់-អាយ៉ាត់

-ចំនួនរ៉ក់អ៊ាត់ ២ (វ៉ាយ៊ីប)
-ចំនួនរូគុអ៊្(ركوع) ១០ (វ៉ាយ៊ីប)
-ចំនួនគូនូត ៥ (ស៊ូណាត់)

បន្ទាប់ពីបាននៀត និងបាន តាក់បីរ៉ទុល អ៊ិះហ្រ៉ាម (تكبيرة الاحرام) ហើយ អ្នកត្រូវសូត្រ ស៊ូរ៉ោះត៍ អាល់-ហ្វាំង៉្ហ រួចហើយសូត្រស៊ូរ៉ោះត៍ណាមួយផ្សេង ។ រួចហើយ រូគុអ៊ ។ (ចប់រូគុអ៊ទីមួយ)

បន្ទាប់ពីបានងើបពីរូគុអ៊ អ្នកត្រូវសូត្រ ស៊ូរ៉ោះត៍ អាល់-ហ្វាំង៉្ហ រួចហើយសូត្រស៊ូរ៉ោះត៍ណាមួយផ្សេង ។ បន្ទាប់មក រូគុអ៊ ម្តងទៀត (ចប់រូគុអ៊ទីពីរ) ។ ធ្វើដូចនេះ ៥ រូគុអ៊ ។

បន្ទាប់ពីបានងើបពីរូគុអ៊ទី ៥ សូត្រថា "សាមីអ៊ុលឡ៉ហ្វ លីម៉ាន់ ហ្វាមីដាស់" ។ រួចហើយធ្វើសាជ់ដាស់ ។ ធ្វើសាជ់ដាស់ទាំងពីរដូចសព្វដង រួចហើយងើបឡើងវិញមកធ្វើរ៉ក់អ៊ាត់ទីពីរដូចរ៉ក់អ៊ាត់ទីមួយដែរ ។

ស៊ូណាត់ឲ្យសូត្រគូនូតមុនរូគុអ៊ គ្រប់ៗពីររូគុអ៊ ។
សរុបមាន ១០ រូគុអ៊ ។ អ្នកសូត្រគូនូតមុនរូគុអ៊ទី ២ និង ទី ៤ ក្នុងរ៉ក់អ៊ាត់ទី១ មុនរូគុអ៊ទី ៦ ទី ៨ និង ទី ១០ ក្នុងរ៉ក់អ៊ាត់ទី ២ ។

## វិធីបំពេញស្ឡ៉ាត់ អាល់-អាយ៉ាត់ខ្លី

គេអនុញ្ញាតឲ្យបំពេញស្វ៍ឡាត្ត៌នេះដែរតាមវិធីខ្លី ។

បន្ទាប់ពីបាន តាក់ប៊ីរ៉ទ្ទុល អ៊ិះហ្ប៍រ៉ម ហើយ ឲ្យអ្នកសូត្រ ស្វ៊ព៉ោះត្ត៍ អាល់-ហ្ប៉ាំង្វ៍ រួចហើយសូត្រ ស្វ៊ព៉ោះត្ត៍ណាមួយផ្សេងទៀតតែមួយប៉ែកទេ ។ រួចហើយ រូគុអ៊ុ ។ ងើបពីរូគុអ៊ុហើយ ឲ្យអ្នកសូត្រប៉ែកទីពីររបស់ស្វ៊ព៉ោះត្ត៍មុន បន្ទាប់មក ធ្វើរូគុអ៊ុទីពីរ ។ ងើបឡើងម្ដងទៀត ហើយសូត្រប៉ែកទីបីរបស់ស្វ៊ព៉ោះត្ត៍មុន បន្ទាប់មក ធ្វើរូគុអ៊ុទីបី ។ ធ្វើដូចគ្នាដែរមុនរូគុអ៊ុទីបួន និង ទីប្រាំ ។ បញ្ចប់ស្វ៊ព៉ោះត្ត៍មុនរូគុអ៊ុទីប្រាំ ។

ឧទាហរណ៍ ស្វ៊ព៉ោះត្ត៍ គ្ទុល ហ្វ៊ូរ៉ល់ឡោះហ្វ៍ ។ អ្នកអាចធ្វើដូចតទៅបាន គឺ៖

- ប៊ិសមិលឡាហ្វ៊ិ ព៉ោះហ្ប៍ម៉ាន នៀររ៉ហ្ប៊ិម មុនរូគុអ៊ុទី ១
- គ្ទុល ហ្វ៊ូរ៉ល់ឡ៏ហ្វ៊ូ អាហ្ប៉ាដ្វ៍ មុនរូគុអ៊ុទី ២
- អល់ឡ៏ហ្វ៊ុស្វ-ស្វ៍ម៉ាដ្វ៍ មុនរូគុអ៊ុទី ៣
- ឡាំ យ៉ាលីដ្វ វាឡាំ យូឡាដ្វ៍ មុនរូគុអ៊ុទី ៤
- វ៉ា ឡាំ យ៉ាគុល ឡាហ្វ៊ូ គូហ្វ៊ូវ៉ាន់ អាហ្ប៉ាដ្វ៍ មុនរូគុអ៊ុទី ៥

ធ្វើបែបនេះ អ្នកសូត្រតែ អាល់-ហ្ប៉ាំង្វ៍ និងមួយស្វ៊ព៉ោះត្ត៍ពេញក្នុងរ៉ក់អ៊ាត្ត់តែមួយ ។ ធ្វើបែបនេះដែរ ៥ រូគុអ៊ុក្នុងរ៉ក់អ៊ាត្ត់ទីពីរ ពីរសាច់ដ្វាស្វ៉ សូត្រតាសាស្វ៉ហ្វ៊ូដ្វ និង សាឡាមដូចសព្វដង ។ ចប់ស្វ៍ឡាត្ត៌ ។

អ្នកអាចជ្រើសរើសយក ស្វ៍ឡាត្ត៌រ៉ក់អ៊ាត្ត់ទី ១ តាមវិធីខ្លី ឯរ៉ក់អ៊ាត្ត់មួយទៀតតាមវិធីធម្មតា (តាមវិធីវែង) ។

## មេរៀនទី ១២

# ស្ជាគីយ៉ាស់ អាល់-ស្វ៍ឡាត់ (១)

ពេលដែលយើងខឹតខំបំពេញស្វ៍ឡាត់យ៉ាងថ្វិតថ្វង់ យ៉ាងយកចិត្តទុកដាក់បំផុត ជួនកាលយើងសង្ស័យអំពីរបៀបធ្វើរបស់យើង ពាក់ព័ន្ធនឹងមួយប៉ែករបស់ស្វ៍ឡាត់ ។ ពេលខ្លះយើងអាចភាន់ច្រឡំក្នុងស្វ៍ឡាត់យើង ។ ប្រសិនបើអ្នកណាកើតមានការសង្ស័យអំពីស្វ៍ឡាត់ អ្នកនោះត្រូវគិតមួយភ្លែតអំពីការសង្ស័យនោះ ហើយខំប្រឹងរំដោះឲ្យរួចផុតការសង្ស័យនោះ ។ បើចៀសមិនផុតពីការសង្ស័យទេ អ្នកនោះត្រូវធ្វើតាមវិន័យដូចតទៅ ។

មាន ២៣ ករណីសង្ស័យ (ស្ជាគីយ៉ាស់ شكية) ដែលអាចកើតមានក្នុងពេលកំពុងបំពេញស្វ៍ឡាត់ ។ មានច្បាប់ស្ជារីអ៊ាស់សម្រាប់ការសង្ស័យនីមួយៗ ។

### ការសង្ស័យដែលគេអាចចោលបាន

មានករណីសង្ស័យ ៦ ដែលអ្នកអាចមិនយកចិត្តទុកដាក់បាន ។ ស្វ៍ឡាត់មិនមោឃៈទេបើមានការសង្ស័យបែបនេះកើតឡើង គឺៈ

១. សង្ស័យក្រោយពីស្វ៍ឡាត់បានចប់ហើយ ។

២. សង្ស័យក្រោយពីបានធ្វើទង្វើរួចទៅហើយ (ឧទាហរណ៍ សង្ស័យនៅពេលដែលកំពុងធ្វើសាច់ដ្ជាស់ ថាបានធ្វើរុគុអ៊ហើយឬទេ) ។

៣. សង្ស័យក្រោយពីពេលស្វ៍ឡាត់បានកន្លងផុតទៅហើយ (ឧទាហរណ៍ ពេលម៉ាក់រីប អ្នកសួរខ្លួនឯងថាតើបានបំពេញស្វ៍ឡាត់អ៊ាស្ស័រហើយឬទេ) ។

៤. បើអ្នកណាសង្ស័យលើសពីមួយដង ក្នុងពេលកំពុងបំពេញស្វ៍ឡាត់ អំពីចំនួន

រ៉ក់អ្នាត់ដែលបានធ្វើរួចមកហើយ អ្នកនោះមិនត្រូវយកចិត្តទុកដាក់ទេ ។

៥. ការសង្ស័យរបស់អ្នកដឹកនាំស្ទ័ឡាត់ (គឺអ៊ីមុាំ) ឬ របស់អ្នកស្ទ័ឡាត់តាមគេ ។ ក្នុងករណីនេះ តើត្រូវយកអ្នកណាដែលជាទីទុកចិត្ត (អ៊ីមុាំ ឬ អ្នកស្ទ័ឡាត់តាមគេ) អ្នកសង្ស័យត្រូវតាមអ្នកណាដែលខ្លួនទុកចិត្ត ។

៦. សង្ស័យក្នុងស្ទ័ឡាត់ស្ងូណាត់ ។

## ការសង្ស័យដែលធ្វើឲ្យស្ទ័ឡាត់មោឃៈ

មានការសង្ស័យ ៨ ប្រការដែលធ្វើឲ្យស្ទ័ឡាត់មោឃៈ។ ក្នុងករណីនេះ ត្រូវបំពេញស្ទ័ឡាត់សាថ្មី ។

១. សង្ស័យអំពីចំនួនរ៉ក់អ្នាត់ក្នុងស្ទ័ឡាត់ដែលមានពីររ៉ក់អ្នាត់ ដូចជាស្ទ័ឡាត់ស៊្មុបហ៊ជាដើម ឬ ពេលអ្នកកំពុងបំពេញស្ទ័ឡាត់អាល់-កូស្ស៊រ៍ របស់ស្ទ័ឡាត់ស៊ុស្វរ៍ អាស្ស៊រ៍ ឬ អ៊ីស្សាអ៊ុំ ។

២. សង្ស័យអំពីចំនួនរ៉ក់អ្នាត់ក្នុងស្ទ័ឡាត់ដែលមានបីរ៉ក់អ្នាត់ ដូចជាស្ទ័ឡាត់ម៉ាក់រីបជាដើម ។

៣. សង្ស័យអំពីចំនួនរ៉ក់អ្នាត់ក្នុងស្ទ័ឡាត់ដែលមានបួនរ៉ក់អ្នាត់ មិនដឹងថាជារ៉ក់អ្នាត់ទី ១ ទី ២ ឬ ទី ៣ ទេ ។

៤. សង្ស័យអំពីចំនួនរ៉ក់អ្នាត់ក្នុងស្ទ័ឡាត់ដែលមានបួនរ៉ក់អ្នាត់ មុនសាច់ដ្ហាស់ទី ២ មិនដឹងថាជារ៉ក់អ្នាត់ទី ២ ឬជារ៉ក់អ្នាត់ទី ៣ ទេ ។

៥. សង្ស័យអំពីចំនួនរ៉ក់អ្នាត់ក្នុងស្ទ័ឡាត់ដែលមានបួនរ៉ក់អ្នាត់ មិនដឹងថាជារ៉ក់អ្នាត់ទី ២ ទី ៥ ឬ មួយរ៉ក់អ្នាត់លើសពីនោះទេ ។

៦. សង្ស័យអំពីចំនួនរ៉ក់អ៊ុត្ត៍ក្នុងស្វ៍ឡាត្ត៍ដែលមានបួនរ៉ក់អ៊ុត្ត៍ មិនដឹងថាជារ៉ក់អ៊ុត្ត៍ទី ២ ទី ៦ ឬ មួយរ៉ក់អ៊ុត្ត៍លើសពីនោះទេ ។

៧. សង្ស័យអំពីចំនួនរ៉ក់អ៊ុត្ត៍ក្នុងស្វ៍ឡាត្ត៍ដែលមានបួនរ៉ក់អ៊ុត្ត៍ មិនដឹងថាជារ៉ក់អ៊ុត្ត៍ទី ៣ ទី ៦ ឬ មួយរ៉ក់អ៊ុត្ត៍លើសពីនោះទេ ។

៨. ភ្លេចចំនួនរ៉ក់អ៊ុត្ត៍ដែលបានធ្វើរួចទៅហើយ ក្នុងស្វ៍ឡាត្ត៍ដែលមានបួនរ៉ក់អ៊ុត្ត៍ ។

**មេរៀនទី ១៣**

# ស្ជាគីយ៉ាស់ អាល់-ស្វ៉ឡាត់(២)

**ស្វ៉ហ៊ិះហ៍ ស្ជាគីយ៉ាស់ ៖ ការសង្ស័យដែលត្រូវតែកែតម្រូវ**

មានការសង្ស័យ ៩ ករណី បើអ្នកកែតម្រូវ ស្វ៉ឡាត់នឹងមិនមោឃៈទេ អ្នកមិនត្រូវបំពេញស្វ៉ឡាត់សាថ្មីទេ ។

១. សង្ស័យក្នុងស្វ៉ឡាត់ដែលមាន ៤ រ៉ក់អាត់ ក្រោយសាជ់ដ្ហាស់ទី ២ ព្រោះតែមិនដឹងថាជារ៉ក់អាត់ទី ២ ឬ ទី ៣ ទេ ។ ក្នុងករណីនេះ ត្រូវចាត់ទុកថាជារ៉ក់អាត់ទី ៣ ហើយចូរបញ្ចប់ស្វ៉ឡាត់ដោយបំពេញរ៉ក់អាត់ទី ៤ ។ បន្ទាប់មកឲ្យអ្នកបំពេញ "ស្វ៉ឡាត់ អាល់-អ៊ិះហ្ទីយ៉ាត់" ១ រ៉ក់អាត់ឈរ ។

២. សង្ស័យក្រោយសាជ់ដ្ហាស់ទី ២ ព្រោះភ្លេចខ្លួន មិនដឹងថារ៉ក់អាត់នេះជារ៉ក់អាត់ទី ២ ឬ ទី ៤ ទេ ។ ក្នុងករណីនេះ ត្រូវចាត់ទុកថារ៉ក់អាត់នេះជារ៉ក់អាត់ទី ៤ ហើយឲ្យអ្នកបំពេញ "ស្វ៉ឡាត់ អាល់-អ៊ិះហ្ទីយ៉ាត់" ២ រ៉ក់អាត់ឈរ ។

៣. សង្ស័យក្រោយសាជ់ដ្ហាស់ទី ២ ព្រោះភ្លេចខ្លួន មិនដឹងថារ៉ក់អាត់នេះជារ៉ក់អាត់ទី ២ ឬទី ៣ ឬទី ៤ ទេ ។ ក្នុងករណីនេះ ត្រូវចាត់ទុកថារ៉ក់អាត់នេះជារ៉ក់អាត់ទី ៤ ហើយឲ្យអ្នកបំពេញ "ស្វ៉ឡាត់ អាល់-អ៊ិះហ្ទីយ៉ាត់" ឈរ ២ រ៉ក់អាត់ រួចហើយឲ្យអ្នកបំពេញ "ស្វ៉ឡាត់ អាល់-អ៊ិះហ្ទីយ៉ាត់" អង្គុយ ២ រ៉ក់អាត់ទៀត ។

៤. សង្ស័យក្រោយសាជ់ដ្ហាស់ទី ២ ព្រោះភ្លេចខ្លួន មិនដឹងថារ៉ក់អាត់នេះជារ៉ក់អាត់ទី ៤ ឬទី ៥ ទេ ។ ក្នុងករណីនេះ ត្រូវចាត់ទុកថារ៉ក់អាត់នេះជារ៉ក់អាត់ទី ៤ ហើយឲ្យអ្នកបញ្ចប់ស្វ៉ឡាត់ភ្លាម ។ រួចហើយ ឲ្យអ្នកធ្វើ "សាជ់ដ្ហាស់ អាល់-សាហ្វ៉ី (سجدة السهو)" ២ ។

៥. សង្ស័យក្រោយសាច់ដ្ញាស់ទី ២ ព្រោះភ្លេចខ្លួន មិនដឹងថារ៉ក់អាត់នេះជារ៉ក់អាត់ទី ៣ ឬទី ៤ ទេ ។ ក្នុងករណីនេះ ត្រូវចាត់ទុកថារ៉ក់អាត់នេះជារ៉ក់អាត់ទី ៤ ហើយឲ្យអ្នកបញ្ចប់ ស្ទ័ឡាត់ភ្លាម ។ បន្ទាប់មក ឲ្យអ្នកបំពេញ "ស្ទ័ឡាត់ អាល់-អ៊ិះហ្វ៊ាទីយ៉ាត់" ឈរ ១ រ៉ក់អាត់ ឬ អង្គុយ ២ រ៉ក់អាត់ ។

៦. សង្ស័យក្នុងពេលគ្វីយ៉ាម ពោលគឺ មុនរូគុអ៍ ព្រោះភ្លេចខ្លួន មិនដឹងថារ៉ក់អាត់នេះជារ៉ក់អាត់ទី ៤ ឬទី ៥ ទេ ។ ក្នុងករណីនេះ ឲ្យអ្នកអង្គុយភ្លាម ហើយបញ្ចប់ស្ទ័ឡាត់ ។ បន្ទាប់ពីនោះ ឲ្យអ្នកបំពេញ "ស្ទ័ឡាត់ អាល់-អ៊ិះហ្វ៊ាទីយ៉ាត់" ឈរ ១ រ៉ក់អាត់ ឬ ២ រ៉ក់អាត់ អង្គុយ ជាមួយ ២ "សាច់ដ្ញាស់ អាល់-សាស្ហ៍វី (سجدة السهو)" ។

៧. សង្ស័យក្នុងពេលគ្វីយ៉ាម ពោលគឺ មុនរូគុអ៍ ព្រោះភ្លេចខ្លួន មិនដឹងថារ៉ក់អាត់នេះជារ៉ក់អាត់ទី ៣ ឬទី ៥ ទេ ។ ក្នុងករណីនេះ ឲ្យអ្នកអង្គុយភ្លាម ហើយបញ្ចប់ស្ទ័ឡាត់ ។ បន្ទាប់ពីនោះ ឲ្យអ្នកបំពេញ "ស្ទ័ឡាត់ អាល់-អ៊ិះហ្វ៊ាទីយ៉ាត់" ឈរ ២ រ៉ក់អាត់ជាមួយ ២ "សាច់ដ្ញាស់ អាល់-សាស្ហ៍វី (سجدة السهو)" ។

៨. សង្ស័យក្នុងពេលគ្វីយ៉ាម ពោលគឺ មុនរូគុអ៍ ព្រោះភ្លេចខ្លួន មិនដឹងថារ៉ក់អាត់នេះជារ៉ក់អាត់ទី ៣ ឬទី ៤ ឬទី ៥ ទេ ។ ក្នុងករណីនេះ ឲ្យអ្នកអង្គុយភ្លាម ហើយបញ្ចប់ស្ទ័ឡាត់ ។ បន្ទាប់ពីនោះ ឲ្យអ្នកបំពេញ "ស្ទ័ឡាត់ អាល់-អ៊ិះហ្វ៊ាទីយ៉ាត់" ឈរ ២ រ៉ក់អាត់ និងអង្គុយ ២ រ៉ក់អាត់ជាមួយ ២ "សាច់ដ្ញាស់ អាល់-សាស្ហ៍វី (سجدة السهو)" ។

៩. សង្ស័យក្នុងពេលគ្វីយ៉ាម ពោលគឺ មុនរូគុអ៍ ព្រោះភ្លេចខ្លួន មិនដឹងថារ៉ក់អាត់នេះជារ៉ក់អាត់ទី ៥ ឬទី ៦ ទេ ។ ក្នុងករណីនេះ ឲ្យអ្នកអង្គុយភ្លាម ហើយបញ្ចប់ស្ទ័ឡាត់ ។ បន្ទាប់មក ឲ្យអ្នកធ្វើ ២ "សាច់ដ្ញាស់ អាល់-សាស្ហ៍វី (سجدة السهو)" ២ ដង សរុបគឺ ៤ "សាច់ដ្ញាស់ អាល់-សាស្ហ៍វី" ។

**មេរៀនទី ១៤**

# ស្វាគីយ៉ាស់ អាល់-ស្វ៉ឡាត់(៣)

**ស្វ៉ឡាត់ អាល់-អ៊ិះហ្វ៉ទីយ៉ាត់ និង សាច់ដ្ងាស់ អាល់-សាស្ហ៍វី** (سجدة السهو)

**ស្វ៉ឡាត់ អាល់-អ៊ិះហ្វ៉ទីយ៉ាត់**

ក្រោយពីបានបញ្ចប់ស្វ៉ឡាត់ មិនបែរចេញគិ្លបឡាត់ ឬ មិនបានធ្វើអ្វីមួយដែលបណ្ដាលឲ្យស្វ៉ឡាត់មោឃៈទេ ឲ្យអ្នកក្រោកឈរ ឬ អង្គុយ ដោយយោលទៅតាមករណី ហើយនៀតថា៖

"ខ្ញុំបំពេញស្វ៉ឡាត់ អាល់-អ៊ិះហ្វ៉ទីយ៉ាត់ ១ ឬ ២ រ៉ក់អាត់ វ៉ាយីប គួរបាតាន់ អ៊ីលឡលឡោះហ្វ ។"

បន្ទាប់មកសូត្រ តាក់ប៊ីរ៉ទុល អ៊ិះហ្វ៉ារ៉ម (تكبيرة الاحرام) ។ សូត្រស្ងាត់ៗស៊ូរ៉ោះត់តែមួយ គឺ អាល់-ហ្វាំដ្វ ។ ចុះរូគុអ៍ រួចហើយធ្វើសាច់ដ្ងាស់ ។ សូត្រតាស្ហាស់ហ្វុដ និង សាឡាម ។ ចប់ស្វ៉ឡាត់ ។

បើអ្នកត្រូវបំពេញស្វ៉ឡាត់ ២ រ៉ក់អាត់ អ្នកត្រូវងើបឡើងវិញដើម្បីបំពេញរ៉ក់អាត់ទី ២ ពេលសាច់ដ្ងាស់រួច ។ សូត្រតែស៊ូរ៉ោះត់ អាល់-ហ្វាំដ្វ មួយទេ ហើយបញ្ចប់ស្វ៉ឡាត់ដូចសព្វដង ។

**សាច់ដ្ងាស់ អាល់-សាស្ហ៍វី** (سجدة السهو)

ចាំបាច់(វ៉ាយីប)ត្រូវធ្វើសាច់ដ្ងាស់ អាល់-សាស្ហ៍វី បើអ្នក ៖

១. និយាយដោយអចេតនាក្នុងពេលកំពុងស្វ៉ឡាត់ ។

២. ភ្លេចដោយអចេតនាសូយូដមួយ ។
៣. ភ្លេចសូត្រតាស្ហាស់ហ៊ុដ ។
៤. សូត្រ "សាឡាម" ខុសកន្លែងដោយអចេតនា ។
៥. បន្ថែម ឬ ភ្លេចធ្វើអ្វីមួយដែលមិនមែនជា "រ៉ូកុន" ដោយអចេតនា ។
៦. ក្នុងស្វឡាត់ដែលមាន ៤ រ៉ក់អាត់ អ្នកសង្ស័យក្រោយពីបានធ្វើសាច់ដាស់ទី ២ រួច ភ្លេចខ្លួន មិនដឹងថារ៉ក់អាត់នេះជារ៉ក់អាត់ទី ៤ ឬទី ៥ ទេ ។

## របៀបធ្វើ សាច់ដាស់ អាល់-សាស្ហ៊ូវី

បន្ទាប់ពីចប់ស្វឡាត់ភ្លាម អ្នកត្រូវនៀតថាៈ "ខ្ញុំធ្វើសាច់ដាស់ អាល់-សាស្ហ៊ូវីជួសតាស្ហាស់ហ៊ុដ (ឬ សាឡាម ឬ សាច់ដាស់ ឬ គ៌ីយ៉ាម ។ល។ យោលតាមករណី) វ៉ាយីប គួរបានតាន់ អ៊ីលឡលឡោះហ៍ ។ បន្ទាប់មក ធ្វើសាច់ដាស់ ក្នុងពេលសាច់ដាស់នេះអ្នកត្រូវសូត្រថាៈ

بِسْمِ اَللّٰهِ وَ بِاللّٰهِ وَ اَلسَّلَامُ عَلَيْكَ أَيُّهَا اَلنَّبِيُّ وَ رَحْمَةُ اَللّٰهِ وَ بَرَكَاتُهُ

"ប៊ិសមិលឡាហ៊ិ វ៉ា ប៊ិលឡាហ៊ិ អាស់សាឡាមុ អាឡៃកា អៃយូហាន់-ណាប៊ីយូ វ៉ា រ៉ោះហ៍ម៉ាទុលឡហ៊ិ វ៉ា បារ៉កាទុះហ៍" ។ បន្ទាប់មក ងើបមកអង្គុយតែមិនសូត្រអ្វីទេ ហើយធ្វើសាច់ដាស់ម្តងទៀត សូត្រក្នុងសាច់ដាស់ នេះដូចមុនដែរគឺៈ

بِسْمِ اَللّٰهِ وَ بِاللّٰهِ وَ اَلسَّلَامُ عَلَيْكَ أَيُّهَا اَلنَّبِيُّ وَ رَحْمَةُ اَللّٰهِ وَ بَرَكَاتُهُ

"ប៊ិសមិលឡាហ៊ិ វ៉ា ប៊ិលឡាហ៊ិ អាស់សាឡាមុ អាឡៃកា អៃយូហាន់-ណាប៊ីយូ វ៉ា រ៉ោះហ៍ម៉ាទុលឡហ៊ិ វ៉ា បារ៉កាទុះហ៍" ។ រួចហើយ ងើបពីសាច់ដាស់ ហើយសូត្រតាស្ហាស់ហ៊ុដនិងសាឡាម ។

បើអ្នកភ្លេចសូត្រតាស្ហាស់ហ៊ុដ ឬ សាច់ដាស់មួយក្នុងស្វឡាត់ ចាំបាច់ត្រូវតែធ្វើសងវិញភ្លាម ក្រោយស្វឡាត់ បន្ទាប់មក ធ្វើ "សាច់ដាស់ អាល់-សាស្ហ៊ូវី" ។

ប្រសិនបើ ក្រោយស្វឡាត់ តែមុនសូត្រតាស្ហាស់ហ៊ុដសង ឬ ធ្វើសាច់ដាស់មួយសងនោះ អ្នកបានធ្វើអ្វីមួយដែលបណ្តាលឲ្យស្វឡាត់មោឃៈ អ្នកចាំបាច់ត្រូវធ្វើសងអ្វីដែលបានភ្លេចនោះ ជាមួយ "សាច់ដាស់ អាល់-សាស្ហ៊ូវី" រួចហើយអ្នកត្រូវបំពេញ

ស្ទ័ឡាត់សាជាថ្មី ។

**មេរៀនទី ១៥**

# គុ្ស៊ល៍ ឬ គុ្ស៊ូល (ស្នានពិធីជម្រះបន្សុទ្ធ)

គុ្សល៍ ឬ គុ្ស៊ូល ជាភាសាអារ៉ាប់ មានន័យថា "ងូតទឹកដើម្បីសម្អាតខ្លួន" ។ ច្បាប់ស្ហារីអ៊ាស្ហ៍ អ៊ីស្លាមបានចែងមកថាជាចាំបាច់(វ៉ាយ៊ីប)ឲ្យងូតទឹកងគុ្ស៊ូលសម្រាប់ឱកាសមួយចំនួន ជាស៊ូណាត់សម្រាប់ឱកាសមួយចំនួនទៀត ។ សម្រាប់ករណីក្រោយនេះ ការងូតទឹកមិនបង្ខំ (ស៊ូណាត់) នាំមកនូវមគ្គផល (ស្ហាវ៉ាប់) ច្រើន ។ ច្បាប់ស្ហារីអ៊ាស្ហ៍បានដាក់មកនូវវិធីងូតទឹក គុ្ស៊ូល មិនអាចប្រតិបត្តិដោយវិធីផ្សេងពីនេះបានជាដាច់ខាត ។

**ប្រភេទគុ្ស៊ូល**

គុ្ស៊ូលវ៉ាយ៊ីបមាន ៧ ប្រភេទគឺៈ

១. យ៉ាណាបាស្ហ៍
២. ម៉ាស់ ម៉ាយិត
៣. ម៉ាយិត
៤. ណាស្ហ៍រ៍(نَذْر) ក៏សាំ(قَسَم) ឬ អាស្ហ៍ដ៍(عَهْد)
៥. អ៊ីសទីហ្វាដ្ហាស្ហ៍(استحاضة)
៦. ហៃដ៍(حيض) } សម្រាប់តែស្ត្រី
៧. នីហ្វាស់(نِفَاس) } សម្រាប់តែស្ត្រី

បួនប្រការមុនប្រើសម្រាប់មនុស្សប្រុសនិងមនុស្សស្រី ឯបីប្រការក្រោយបានតែលើមនុស្សស្រីទេ ។

គុ្ស៊ូល ស៊ូណាត់មានច្រើន តែគុ្ស៊ូលសំខាន់ជាងគេគឺគុ្ស៊ូល យ៉ូមអ៊ាត់(ងូតទឹកថ្ងៃសុក្រ) ។ គុ្ស៊ូលនេះម៉ាក៉ុស្ហមីនﷺបានផ្តាំផ្ញើឲ្យធ្វើ ។ គុ្ស៊ូលឯទៀតគឺ គុ្ស៊ូល "អ៊ីដ្ហ អ៊ុល-ហ្វីត្រី" និង គុ្ស៊ូល "អ៊ីដ្ហ អ៊ុល អាដ្ហ៍ហ្វា"

## លក្ខខណ្ឌ (ស្ហារ៉ត្ហ شرط) របស់គូស្ល៊ូល

ក) ទឹកសម្រាប់គូស្ល៊ូលត្រូវតែ្ហហូរ៉ (បរិសុទ្ធ) មុត្ហឡាក់ (គឺទឹកបរិសុទ្ធ មិនលាយអ្វីផ្សេង) និង មូបាស្ហ (អនុញ្ញាត) ។

ខ) កន្លែងដែលងូតទឹកគូស្ល៊ូលត្រូវមូបាស្ហ ដូចគ្នាដែរសម្រាប់របស់ប្រើប្រាស់ (ដូចជាធុងទឹកជាដើម) ដែលអ្នកប្រើក្នុងការងូតទឹកគូស្ល៊ូលនេះ ហើយមិនធ្វើអំពីមាសឬប្រាក់ទេ ។

គ) មុនងូតទឹកគូស្ល៊ូល ខ្លួនអ្នកត្រូវបរិសុទ្ធសិន អស់ណាយ៉ិស (ដូចជា ឈាមហ្ស៊ៃជ៏ ទឹកកាម ។ល ។)

ឃ) ត្រូវធ្វើគូស្ល៊ូលក្នុងគោលបំណង **គួរបាតាន់ អ៊ីលឡលឡោះហ្ស៍** ពោលគឺ ដើម្បីផ្គាប់ចិត្តអល់ឡោះហ្វ៍ﷻនិងគោរពតាមបង្គាប់ព្រះអង្គﷻ ។

ង) ត្រូវងូតទឹកគូស្ល៊ូលដោយខ្លួនឯង មិនឲ្យគេជួយទេ លើកលែងតែអ្នកមានជម្ងឺ ។

ច) ការប្រើទឹកក្នុងស្ពានពិធីគូស្ល៊ូល មិនបណ្តាលឲ្យមានគ្រោះថ្នាក់ដល់សុខភាពអ្នកទេ ។

ឆ) ត្រូវយកចេញនូវសារធាតុប្រេង ភាពកខ្វក់ ឬ សារធាតុផ្សេងៗដែលអាចឃាត់ទឹកមិនឲ្យប៉ះស្បែកបាន ។ ដូច្នេះ ត្រូវយកចេញឲ្យអស់នូវប្រេងលាបសក់ ថ្នាំលាបក្រចក ក្រមួនលាបបបូរមាត់ មុននឹងបំពេញស្ពានពិធីគូស្ល៊ូល ។

## វិធីបំពេញស្ពានពិធីគូស្ល៊ូល

មានវិធីពីរ គឺៈ

១. **គូស្ល៊ូល តារទីប៊ី** (غسل ترتيبى) ពោលគឺ តាមលំដាប់ ។

ជាដំបូង លាងក្បាលទាំងស្រុងដល់ក ។ បន្ទាប់មក លាងប៉ែកខ្លួនដែលនៅសល់នោះ ឬ អ្នកអាចលាងខ្លួនបានតាម ២ លំដាប់ ។ ដំបូង លាងប៉ែកខាងស្តាំខ្លួន រាប់បញ្ចូលខ្មាសផង ។ បន្ទាប់មក លាងប៉ែកខាងឆ្វេងខ្លួន រាប់បញ្ចូលខ្មាសផង ។

២. **គូស្ហ៊ូល អៀរទីម៉ាស៊ី** (غسل ارتماسي) ពោលគឺមុជក្នុងទឹក ។

គូស្ហូលនេះប្រព្រឹត្តទៅដោយលាងខ្លួនទាំងអស់តែមួយដង ។ អាស្រ័យហេតុនេះ គូស្ហូលនេះនឹងប្រព្រឹត្តទៅដោយមុជទាំងខ្លួនតែម្តងក្នុងស្ទឹង ក្នុងសមុទ្រ ឬ ក្នុងអាងហែលទឹក ។

## គូស្ហ៊ូលវ៉ាយ៉ិប

ស្ត្រីពេញវ័យគ្រប់រូបដែលមានសុខភាពល្អបាត់បង់ឈាមរដូវខែ ។ មុនស្វ៍ឡាត់ ស្ត្រីត្រូវជម្រះបន្សុទ្ធពីឈាមរដូវខែនេះសិន ។

ស្ត្រីមានឈាមរដូវខែ ៣ ប្រភេទដែលហៅថា៖ ហៃហ្ទ៍ (حيض) អ៊ីសទីហ្ទាដ្ហាស្ទ់(استحاضة) និង នីហ្វាស (نفاس) ។ ការជម្រះបន្សុទ្ធដែលតម្រូវឲ្យធ្វើនោះគឺ គូស្ហូល (ស្ពានពិធីជម្រះបន្សុទ្ធ) ។

នីហ្វាស (نفاس) គឺការបាត់បង់ឈាមក្រោយពីបានសម្រាលកូនរួច ។ មិនមានរយៈពេលតិចសម្រាប់នីហ្វាសទេ តែចំនួនថ្ងៃដែលជារយៈពេលច្រើនបំផុតដែលមាននីហ្វាសគឺ ១០ ថ្ងៃ ។

## ហៃហ្ទ៍

មានន័យថា "មានឈាមរដូវខែ" ដែលហៅជាសាមញ្ញថា "រដូវ" ។

១. ឈាមដែលមានមុនអាយុ ៩ ឆ្នាំ និងក្រោយអាយុ ៥០ ឆ្នាំ មិនមែនហៃហ្ទ៍ទេ ។

គេហៅឈាមនេះថា អ៊ីសទីហ្កាដ្ហាស្ទ៍(استحاضة) ។

២. រយៈពេលធ្លាក់ឈាមហៃដ្ទ៍នៅក្នុងចន្លោះថ្ងៃទី ៤ និងថ្ងៃទី ១០ យ៉ាងយូរ ។ ធ្លាក់ឈាមតិចជាង ៣ ថ្ងៃ ឬ លើសពី ១០ ថ្ងៃ ហៅថា អ៊ីសទីហ្កាដ្ហាស្ទ៍(استحاضة) ។

៣. មានច្បាប់លំអិតពន្យល់ស្ត្រីមានហៃដ្ទ៍នូវវិធីអនុវត្តិពេលមានរដូវ ឬគ្មានរដូវ ពេលមានរដូវដំបូង ពេលភ្លេចថ្ងៃ ឬភ្លេចចំនួនថ្ងៃដែលមានរដូវ ។ នឹងអធិប្បាយលំអិតអ្វីទាំងនេះនៅពេលខាងមុខ ។

**ស្ហាទុល អាដ្ហាស្ទ៍** (ذات العادة)

ពាក្យសម្រាប់ហៅស្ត្រីដែលមានរដូវខែក្នុងចំនួនថ្ងៃឥតប្រែប្រួលរៀងរាល់ខែ ។

**ស្ហាទុល-វ៉ាក់ទ៍** (ذات الوقت)

ពាក្យសម្រាប់ហៅស្ត្រីដែលចាប់ផ្តើមមានរដូវខែរាល់ខែក្នុងថ្ងៃដដែលៗ (ឧទាហរណ៍ រៀងរាល់ថ្ងៃទី ៥) ។

**ស្ហាទុល-វ៉ាក់ទ៍ វ៉ាល់-អាដ្ហាស្ទ៍**

គឺស្ត្រីដែលចាប់ផ្តើមមានរដូវខែរៀងរាល់ខែថ្ងៃដដែលៗ ហើយមានចំនួនថ្ងៃរបស់រដូវខែនោះមិនផ្លាស់ប្តូរ ។

**មុបតាឌីអាស្ទ៍** (المبتدئة)

គឺស្ត្រីក្មេងដែលទើបនឹងមានរដូវខែជាលើកដំបូង ។

**មុដ្ហត្ថ័របាស្ទ៍** (المضطربة)

ពាក្យសម្រាប់ហៅស្ត្រីដែលថ្ងៃនិងចំនួនថ្ងៃរបស់រដូវខែនោះមិនទាន់ទៀង ។

**ណាសុីយ៉ាស្ទ៍** (الناسية)

ពាក្យសម្រាប់ហៅស្ត្រីដែលភ្លេចថ្ងៃ ឬភ្លេចពេលដែលចាប់ផ្តើមមានរដូវខែនិងចំនួនថ្ងៃរបស់រដូវខែនោះ ។

**ណាសុីយ៉ាទុល-វ៉ាក់ត៍**

គឺស្ត្រីដែលភ្លេចថ្ងៃដែលរដូវខែចាប់ផ្តើមមានជាធម្មតា ។

**ណាសុីយ៉ាទុល-អាទ្ទាស្ទ**

គឺស្ត្រីដែលភ្លេចចំនួនថ្ងៃដែលមានរដូវខែ ។

**ណាសុីយ៉ាទុល-វ៉ាក់ត៍ វ៉ាល់-អាទ្ទាស្ទ**

ពាក្យសម្រាប់ហៅស្ត្រីដែលភ្លេចទាំងថ្ងៃដែលចាប់ផ្តើមមានរដូវខែ ទាំងចំនួនថ្ងៃដែលមានរដូវខែនោះ ។

**អុីសទីហ្ទាដ្ទាស្ទ**(استحاضة)

ការធ្លាក់ឈាមដែលមិនមែនហៃដ្ទ៍ និងមិនមែននីហ្វាស់ ។ មាន ៣ ប្រភេទគឺៈ

១. **អុីសទីហ្ទាដ្ទាស្ទ ក៏លីឡាស្ទ** (استحاضة قليلة - អុីសទីហ្ទាដ្ទាស្ទតូច) គឺឈាមដែលមិនជ្រាបចូលទៅក្នុងក្រណាត់អនាម័យ ។ មិនមានគូស្លលើប្រភេទអុីសទីហ្ទាដ្ទាស្ទនេះទេ តែស្ត្រីត្រូវយកទឹកវូឌុអ៏សម្រាប់ស្ទឡាត់នីមួយៗ ។ មិនអនុញ្ញាតឲ្យនាងបំពេញស្ទឡាត់ពីរ ដោយយកទឹកវូឌុអ៏តែម្តងនោះទេ (ឧទាហរណ៍ បើនាងបំពេញស្ទឡាត់អាស្ទវ័ភ្លាម ក្រោយស្ទឡាត់ស៊ុស្ទរ៍ នាងត្រូវយកទឹកវូឌុអ៏ម្តងទៀតសម្រាប់ស្ទឡាត់អាស្ទវ័) ។

២. **អុីសទីហ្ទាដ្ទាស្ទ មូតាវ៉ាស់សុីតោះត៍** (استحاضة متوسطة - អុីសទីហ្ទាដ្ទាស្ទកណ្តាល) គឺឈាមដែលជ្រាបចូលទៅក្នុងក្រណាត់អនាម័យតែមិនហៀរទេ ។ ប្រភេទអុីសទីហ្ទាដ្ទាស្ទនេះតម្រូវឲ្យស្ត្រីយកទឹកវូឌុអ៏សម្រាប់ស្ទឡាត់នីមួយៗ ហើយងូតទឹកគូស្លមួយដងក្នុងមួយថ្ងៃ (ឧទាហរណ៍ បើនាងឃើញមានអុីសទីហ្ទាដ្ទាស្ទប្រភេទនេះមុនស្ទឡាត់ស៊ុស្ទរ៍ នាងត្រូវងូតទឹកគូស្លមុនស្ទឡាត់ស៊ុស្ទរ៍ បំពេញស្ទឡាត់ស៊ុស្ទរ៍ជាមួយគូស្លនេះនិងវូឌុអ៏) ។ ស្ទឡាត់ឯទៀតរហូតដល់ពេលហ្វាច់រ៍ថ្ងៃស្អែកត្រូវបំពេញដោយយកទឹកវូឌុអ៏ សម្រាប់

ស្វ៍ឡាត់នីមួយៗ ។

៣. **អ៊ីសទីហ្វាដ្វាស់ កាស៊្ទីរ៉ោះត៍** (استحاضة كثيرة - អ៊ីសទីហ្វាដ្វាស់ធំ) គឺឈាម ដែលហៀរពីក្រណាត់អនាម័យ ក្រោយពីបានទទឹកក្រណាត់អនាម័យនោះហើយ ។ ស្ត្រីពាក់ព័ន្ធនឹងអ៊ីសទីហ្វាដ្វាស់ប្រភេទនេះ ត្រូវយកទឹកវូឌុអ៍សម្រាប់ស្វ៍ឡាត់នីមួយៗ ហើយងូតទឹកគុស្វូល ៣ ដងក្នុងមួយថ្ងៃគឺៈ គុស្វូលមួយសម្រាប់ស្វ៍ឡាត់ហ្វាច់រ៍ មួយទៀតសម្រាប់ស្វ៍ឡាត់ស៊ុហរ៍និងអាស្វ័រ និងមួយទៀតសម្រាប់ស្វ៍ឡាត់ម៉ាក់រិបនិងអ៊ីស្វាអ៍ ។

## សេចក្តីបញ្ជាក់

១. គ្រប់ករណី ចាំបាច់បំផុតឲ្យស្ត្រីដូរក្រណាត់អនាម័យរាល់វូឌុអ៍ ។
២. ប្រសិនបើ ដោយមូលហេតុណាមួយ ស្ត្រីមិនអាចយកទឹកវូឌុអ៍ឬគុស្វូលបានទេ ឲ្យធ្វើតាយ៉ាំជំនួសវូឌុអ៍ឬគុស្វូល ។
៣. បើស្ត្រីគោរពតាមច្បាប់ខាងលើនេះ នាងត្រូវចាត់ទុកថាត៍ហ្វៀរហើយ (គឺបរិសុទ្ធ) ។

## ទង្វើដែលត្រូវហាម (ហ្វារ៉ាំ) ពេលមានហៃ្វដ៍និងនីហ្វាស់

១. សូត្រស្វ៉ោះត៍ណាមួយដែលមានសាច់ដ្វាស់វ៉ាយ៉ីប ។
២. ប៉ះព្រះអក្សរពិសិដ្ឋរបស់គួរអានឬព្រះនាមអល់ឡោះហ្វ៍ﷻ ព្រះនាមបណ្តាព្រះសាស្តា ឬ បណ្តាអ៊ីមុាំ នៅក្នុងសៀវភៅណាក៏ដោយ ។
៣. ចូលទៅក្នុងម៉ាស់យ៉ីដណាក៏ដោយ ។ បើចាំបាច់ណាស់ អ្នកអាចដើរកាត់ម៉ាស់យ៉ីដបាន ដោយមិនឈប់ ។ សម្រាប់ម៉ាស់យ៉ីដ ណាបាវី និងម៉ាស់យ៉ីឌុល-ហ្វារ៉ម ទោះបីដើរកាត់ក៏ដោយក៏ត្រូវហាមដែរ ។
៤. ដាក់អ្វីមួយនៅក្នុងម៉ាស់យ៉ីដពីខាងក្រៅ ចូលទៅក្នុងម៉ាស់យ៉ីដដើម្បីយកអ្វីមួយចេញមកខាងក្រៅផងដែរ ។

## ទង្វើម៉ាក់រុះហ្វ៍ពេលមានហៃ្វដ៍និងនីហ្វាស់

១. ស្ងួតអាយ៉ាស់គួរអានលើសពី ៧ អាយ៉ាស់ ។
២. ប៉ះគួរអាន ។
៣. កាន់គួរអាន ឬ យកគួរអានពីកន្លែងមួយទៅកន្លែងមួយទៀត ទោះបីមិនប៉ះក៏ដោយ ។

ស្ត្រីដែលមានហៃដ្ធ ឬ នីហ្វាស់ត្រូវអនុញ្ញាតឲ្យខានបំពេញស្ហ្វឡាត់និងកាន់សីលត្រណមអាហារបាន ។ នាងមិនបាច់បំពេញស្ហ្វឡាត់ក៏ដ្ធជួសស្ហ្វឡាត់ដែលមិនបានបំពេញនៅក្នុងអំឡុងពេលមានហៃដ្ធឬនីហ្វាស់នោះទេ ។ ក៏ប៉ុន្តែនាងត្រូវសងសីលត្រណមអាហារដែលបានខាននោះ ។

--

## លំហាត់ ១

១. មានព្រឹត្តិការណ៍សំខាន់ៗច្រើនក្នុងខែរ៉ម៉ាដ្ធន ។ ចូរដាក់ព្រឹត្តិការណ៍ផ្សេងនៅខាងឆ្វេងឲ្យត្រូវនឹងថ្ងៃរបស់វាដែលនៅខាងស្ដាំ ។

| **ព្រឹត្តិការណ៍** | **ថ្ងៃទីក្នុងខែរ៉ម៉ាដ្ធន** |
|---|---|
| ចម្បាំងនៅសមរភូមិបាដ្ធារ | ២១ |
| ប៊ីប៊ីខ៍ឌីយ៉ាស្ទ៍ ﷺ ចូលទិវង្គត | ១៩ |
| យប់ឡៃឡាទុ្ទល-កដ្ធ៍រ៍ | ១៥ |
| អ៊ីម៉ាំអាុលី صلوات الله عليه والسلام ចូលទិវង្គត | ១០ |
| ថ្ងៃប្រសូតអ៊ីម៉ាំហ្ាសាន់ صلوات الله عليه والسلام | ១៩, ២១, ២៣ |
| អាុលី صلوات الله عليه والسلام ត្រូវរបួសក្នុងម៉ាស់យ៉ិដ្ធគូហ្វាស្ទ៍ | ១៧ |

២. ឈ្មោះមួយទៀតរបស់សីលត្រណមអាហារគឺ_______ ។ គេត្រូវ__________ (គួរបាតាន់ អ៊ីលឡុលឡោះហ្វ៍) កាន់សីលត្រណមអាហារនៅដើមខែរ៉ម៉ាដ្ធន ឬនៅពេលមុនថ្ងៃនីមួយរបស់ខែរ៉ម៉ាដ្ធន ។ សីលត្រណមអាហារចាប់ផ្ដើម__________ ចប់_______ ។ បើសីលត្រណមចាប់ផ្ដើមនៅពេលព្រឹកម៉ោង ៦:០០ ពេលអ៊ីមសាក់ព្រឹកគឺ________ ។

៣. ផ្ដល់មូលហេតុកាន់សីលត្រណមអាហារ ។

## លំហាត់ ២

១. ពាក្យតទៅនេះមានន័យថាអ្វី គឺ៖ វ៉ាយ៉ិប, ស្ទូណាត់្ទ៍, ម៉ាក់រុះហ្វ៍, ហ្ារ៉ាំ ?

២. តើសីលប្រោមអាហារខាងក្រោមជាសីលត្រណមអាហារវ៉ាយ៉ិប (វ), ស្ទូណាត់្ទ៍ (ស), ម៉ាក់រុះហ្វ៍ (ម), ឬ ហ្ារ៉ាំ (ហ) ? ចូរសរសេរឈ្មោះរបស់ឱកាសកាន់សីលត្រណមនោះផង ។

វ, ស, ម, ហ និង ឈ្មោះរបស់ឱកាសកាន់សីលត្រណម

ក) ១ ស្ងោវ៉ាល់______និង____________________ ។
ខ) ២១ មីនា____និង_____________________ ។
គ) ២៧ រ៉យ៉ាប់____និង_____________________ ។
ឃ) ១០ មូហ្វាររ៉ម____និង_______________________ ។
ង) ២៧ រ៉យ៉ាប់____និង_______________________ ។
ច) ១៥ ស្វាបាន____និង_____________________ ។
ឆ) ១០ ស៊្ញុល-ហ៊្វីច្ចយ៉ាស្វ____និង_____________________ ។
ជ) ២៤ ស៊្ញុល-ហ៊្វីច្ចយ៉ាស្វ____និង_____________________ ។
ឈ) ១៨ ស៊្ញុល-ហ៊្វីច្ចយ៉ាស្វ____និង_____________________ ។
ញ) ១០ រ៉ម៉ាដ្វន____និង_____________________ ។

## លំហាត់ ៣

១. ចូរអធិប្បាយអំពីផលវិបាកលើសីលត្រណមអាហារ (តើសីលត្រណមត្រូវមោឃៈឬទេ) ដោយសារទង្វើខាងក្រោមនេះគឺៈ

ក) មុជក្នុងទឹកដល់ដើមទ្រូងដោយចេតនា ។
ខ) ភ្លេចថាខ្លួនកំពុងកាន់សីលត្រណមអាហារ ក៏លីបបានផឹកទឹក ។
គ) អ្នកប្រើច្រាសដុសធ្មេញសម្រាប់ដុសធ្មេញ ។
ឃ) អ្នកនៅតែណាត់ជួបពេទ្យធ្មេញ ទោះបីដឹងថាពេទ្យនោះនឹងដកធ្មេញអ្នកក៏ដោយ ដែលនឹងធ្វើឲ្យចេញឈាម ។
ង) អ្នកចង្អោរដោយសារមានបញ្ហាសុខភាពយ៉ាងទាន់ហន់ ។
ច) អ្នកហែលទឹកក្នុងខែរ៉ម៉ាដ្វន មុជក្បាលមួយដងមួយកាល តែចៀសវាងមិនឲ្យទឹកចូលត្រចៀកឬចូលមាត់ទេ ។
ជ) អ្នកហាត់កីឡានៅឯសាលារៀនដោយដឹងច្បាស់ថា វានឹងធ្វើឲ្យអ្នកអស់កម្លាំង ។

ឈ) អ្នកចូលទៅក្នុងផ្ទះបាយ ក្លិនចំណីថ្មីៗធ្វើឲ្យអ្នកមានកម្លាំង ។

ញ) អ្នកជួយយកអាសាអ្នកលង់ទឹកដោយមុជក្នុងអាងហែលទឹក ។

ដ) អ្នកជក់បារី ។

ឋ) មិត្តរបស់អ្នកដែលមិនមែនមុស្លីមចង់កាន់សីលត្រណមអាហារ ព្រោះចង់ដឹងចង់ស្គាល់ ។

## លំហាត់ ៤

ចូរដោះស្រាយបញ្ហាខាងក្រោមនេះគឺៈ

១. តារបស់ត្វ័លីបដែលមានអាយុ ៨០ ឆ្នាំគិតថានឹងពិបាកកាន់សីលត្រណមអាហារក្នុងខែរ៉ម៉ាដូនណាស់ ។

២. អាលីមានជម្ងឺតម្រងទឹកនោម បានខានកាន់សីលត្រណមអាហារ ១០ ថ្ងៃក្នុងខែរ៉ម៉ាដូន ។
ហ្វីដ្យយ៉ាស្ហ(الفدية)មួយភាគ (១ មុដ្ឋ-مُدّ = ៧៥០ ក្រាម) មានតម្លៃ ២ អឺរ៉ូ ។
តើហ្វីដ្យយ៉ាស្ហរបស់អាលីសរុបទៅថ្លៃប៉ុន្មាន ?
តើអាលីត្រូវកាន់សីលត្រណមអាហារក៏ដ៏ទេ ឬ តើហ្វីដ្យយ៉ាស្ហគ្រប់ទេ ?

៣. អ្នកមិនបានកាន់សីលត្រណមអាហារឆ្នាំ ២០១២ ព្រោះអ្នកមានជម្ងឺធ្ងន់ ។ អ្នកបានសងសីលត្រណមនេះក្នុងខែស្ហ៍ហ្បារ ឆ្នាំ ២០១៣ ។ តើអ្នកត្រូវបង់ហ្វីដ្យយ៉ាស្ហថែមពីលើសីលត្រណមក៏ដ៏នេះទេ ? ចូរអធិប្បាយចម្លើយអ្នក ។

៤. ក្នុងករណីខាងលើនេះ តើមានបញ្ហាទេបើអ្នកក៏ដ៏សីលត្រណមក្នុងខែស្ហៅវ៉ាល់ ២០១៣ ? តើអ្នកបង់ហ្វីដ្យយ៉ាស្ហទេ ?

៥. អ្នកណាម្នាក់ត្រូវបង់កាហ្វ៉ាហ្វារ៉ោះត្ហ៍(كفارة) ៦០ ថ្ងៃ ។ អ្នកនោះចង់ចាប់ផ្តើមកាន់សីលត្រណមចាប់ពីថ្ងៃទី ១ ខែស្ហុល-ហុិច្ចយ៉ាស្ហ ។ តើអ្នកឲ្យយោបល់អ្វីដល់អ្នកនោះ ? នេះគឺគន្លឹះមួយសម្រាប់ដោះស្រាយបញ្ហានេះ ៖ អុីដុ អុិល អាដ់ហ្ហា

ប្រព្រឹត្តិទៅនាថ្ងៃទី ១០ ខែស្សុល-ហ៊ិជ្ជះយ៉ាស្វ ។

៦. ខែរ៉ម៉ាជ្ជន អ្នកបានសម្រេចចិត្តធ្វើដំណើរថ្ងៃស្អែក ។ យន្តហោះចេញដំណើរម៉ោង ៩ អ្នកងើបពីដំណេកម៉ោង ៨ ដើម្បីស្រស់ស្រូប ។ តើអល់ឡោះហ្វ៍នឹងដាក់ទណ្ឌកម្មអ្នកទេព្រោះតែបានបរិភោគ ។ បើអល់ឡោះហ្វ៍ធ្វើទណ្ឌកម្មមែន ចូរអធិប្បាយលម្អិតចម្លើយអ្នក តើអ្នកនឹងសងទង្វើនេះដូចម្តេច ? បើអល់ឡោះហ្វ៍មិនធ្វើទណ្ឌកម្មទេ ហេតុអ្វី ?

៧. ទង្វើខាងក្រោមនេះ ដែលបានប្រព្រឹត្តិក្នុងពេលកាន់សីលត្រណមអាហារខែរ៉ម៉ាជ្ជន តើអ្នកត្រូវបង់កាហ្វហ្វារ៉ោះត៍មួយ ឬ បីកាហ្វហ្វារ៉ោះត៍ គឺះ

ក) ផឹកទឹក ។

ខ) ផឹកស្រា ។

គ) និយាយកុហកទម្លាក់លើអល់ឡោះហ្វ៍ ﷻ លើព្រះសាស្តា ﷺ ព្រះអង្គ ﷻ និងលើម៉ាក់ស្ហូមីន ﷷ ។

## លំហាត់ ៥

តើអ្នកឲ្យយោបល់អ្វីក្នុងស្ថានការណ៍ខាងក្រោមនេះគឺះ

១. អ្នកឈឺក្នុងខែរ៉ម៉ាជ្ជន ហើយបានស្លាប់មុនផុតខែនេះ តើវ៉ាលីយ្យបឲ្យកូនប្រុសបងគេបង្អស់របស់គាត់កាន់សីលត្រណមអាហារកឺ្វជ្ជំឲ្យគាត់ទេ ?

២. អ្នកមានជម្ងឺតាំងពី ២០ ឆ្នាំមកហើយដែលមិនអាចកាន់សីលត្រណមអាហារបាន ស្រាប់តែជាពីជម្ងឺ ។ អ្នកនោះត្រូវធ្វើយ៉ាងណាពាក់ព័ន្ធនឹងសីលត្រណមអាហារកឺ្វជ្ជំ ២០ ឆ្នាំមុន ។

៣. អ្នកកាហ្វៀរបានទៅជាមុស្លីម មិនប្រាកដថានឹងត្រូវកាន់សីលត្រណមអាហារទាំងអស់សងដែលខ្លួនមិនបានធ្វើនោះឬទេ កាលដែលនៅជាកាហ្វៀរ ?

៤. អ្នកផ្តាច់ត្រណមព្រោះស្មានថាដល់ពេលអ៊ីហ្វតារហើយ តែក្រោយមកអ្នកដឹងថាមិនទាន់ដល់ពេលស្រាយទេ ។ តើអ្នកត្រូវកាន់សីលត្រណមអាហារក្ឌ៉ាដ៏ទេ ? តើវ៉ាយ៉ីបតម្រូវឲ្យអ្នកធ្វើទេ ?

៥. ប្អូនអ្នកអាយុ ៩ ឆ្នាំកាន់សីលត្រណមអាហារ ។ នៅសាលាគ្រូវាបានបង្ខំវាឲ្យឈប់កាន់សីលត្រណមអាហារដោយមូលហេតុមិនត្រឹមត្រូវ ។ តើវ៉ាយ៉ីបតម្រូវឲ្យវាកាន់សីលត្រណមអាហារក្ឌ៉ាដ៏ទេ ?

## លំហាត់ ៦

១. យ៉ាវ៉ាដ៉ូចង់ទៅកន្លែង(ក)ដែលមានចម្ងាយ ១៦ គ.ម. ។ ពេលទៅដល់ទី(ក) គាត់សម្រេចចិត្តបន្តដំណើរទៅមុខទៀតរហូតដល់ទី(ខ) ។ ដំណើរនេះមានចម្ងាយសរុប ៦៤ គ.ម. ។ ក្នុងករណីទាំងពីរ ចូរអធិប្បាយចម្លើយអ្នក ។

ក) គាត់គប្បីបំពេញស្វ៉ាឡាត់ អាល់-កូស៊្វ៉រ ឬ ស្វ៉ាឡាត់ពេញ(ធម្មតា)ពេលទៅដល់ទីដៅ (ក) ?

ខ) គាត់គប្បីបំពេញស្វ៉ាឡាត់ អាល់-កូស៊្វ៉រ ឬ ស្វ៉ាឡាត់ពេញ(ធម្មតា)ពេលទៅដល់ទីដៅ (ខ) ?

២. យ៉ាវ៉ាដ៉ូតែងតែទៅលេងម្ដាយធំ បងប្រុសខ្លួន ដែលរស់នៅឆ្ងាយពីនោះ ២៤ គ.ម. ។ ព្រោះតែទៅលេងទីនោះយ៉ាងទៀងទាត់បានជាយ៉ាវ៉ាដ៉ូរកផ្លូវជិតមួយឃើញសម្រាប់ត្រឡប់មកផ្ទះវិញ ចំណេញ ៣,២០ គ.ម. លើចម្ងាយផ្លូវសរុប ។ ក្នុងឱកាសពិសេស យ៉ាវ៉ាដ៉ូបានស្នាក់នៅផ្ទះម្ដាយធំ ៧ ថ្ងៃ ។ តើយ៉ាវ៉ាដ៉ូត្រូវបំពេញស្វ៉ាឡាត់អាល់-កូស៊្វ៉រ ទេពេលស្នាក់នៅឯផ្ទះម្ដាយធំ ? ចូរអធិប្បាយចម្លើយអ្នក ។

៣. អចលនទ្រព្យមួយដែលបានមកដោយលំអៀងគេត្រូវគេដាក់លក់នៅឯ ៥៦០ គ.ម.ពីផ្ទះរបស់អ៊ូម៉ារ ។ បានសម្រេចចិត្តទៅទិញរបស់នោះ ។ អ៊ូម៉ារស្នាក់នៅទី

នោះ ២ ថ្ងៃ ។ តើអ្នកម៉ារគប្បីបំពេញស្វ័ឡាត់អាល់-កូស្ស៊ូរ៍ ទេក្នុងអំឡុងពេលស្នាក់នៅទីនោះ ? ចូរអធិប្បាយចម្លើយអ្នក ។

៤. ក្រុមកីឡាបាល់ទាត់ ម៉ាដ្ឋរ៉ាសាស្ស៊ អ៊ីស្លាម អ៊ីស្ស៊ណា អាស្ស៊អារីយ៉ាស៊ូបាន សម្រេចចិត្តទៅប្រកួតកីឡានៅឯក្រៅប្រទេស ។ ពួកគេគិតស្នាក់នៅមួយសប្តាហ៍ ។ តើពួកគេគប្បីបំពេញស្វ័ឡាត់អាល់-កូស្ស៊ូរ៍នៅទីនោះទេ ?

៥. ក៏ប៉ុន្តែ ថ្ងៃទី ៧ ការសមកីឡារបស់ពួកគេត្រូវមោឃៈ ពួកគេត្រូវស្នាក់នៅ ៤ ថ្ងៃថែមទៀត ។ តើពួកគេត្រូវបំពេញស្វ័ឡាត់ធម្មតា ឬ បង្រួញ ក្នុងអំឡុងពេល ៤ ថ្ងៃនោះ ? ចូរអធិប្បាយចម្លើយអ្នក ។

## លំហាត់ ៧

ចូរបំពេញចន្លោះទទេ ។

១. អ្នកណាមិនកាន់សីលត្រណមអាហារដោយស្ម័គ្រចិត្តក្នុងខែរ៉ម៉ាដ្ឋន អ្នកនោះត្រូវ ________________ និង______________ ។

២. នៅគ្រប់ទីកន្លែងដែលអ្នក______________ អ្នកមិនកាន់សីលត្រណមអាហារទេ ។

៣. ស្វ័ឡាត់ប្រចាំថ្ងៃទាំង ៥ សរុបមាន_________រ៉ក់អាត់ ។ ក៏ប៉ុន្តែ ពេលអ្នកបំពេញស្វ័ឡាត់បង្រួញ (អាល់-កូស្ស៊ូរ៍) ចំនួនសរុបស្វ័ឡាត់ទាំងនេះមាន _________រ៉ក់អាត់ទេ ។

៤. ចូរបំពេញបញ្ជីខាងក្រោមនេះ ។

| ចំនួនស្វ័ឡាត់ធម្មតា | ចំនួនស្វ័ឡាត់បង្រួញ (អាល់-កូស្ស៊ូរ៍) |
|---|---|

ស្ទុបហ្ ______________________
ស៊ុស្វរ៍ ______________________
អ៊ុស្វ៉រ៍ ______________________
ម៉ាក្ទ៉រីប ______________________
អ៊ីស្វាអ៊ ______________________

៥. ____________________គឺកន្លែងដែលជាចុងបំផុតរបស់ព្រំប្រទល់ស្រុក ។

៦. អ្នកដំណើរអាចជ្រើសរើសយកស្វ៍ឡាត៉ពេញ ឬ ស្វ៍ឡាត៉បង្រួញបាននៅ _______ ឬ_____________ ។

៧. _____អ៊ីស្លាមចាប់ផ្ដើមនៅពេលមើលឃើញចំណិតខែដំបូងបង្អស់ មិន _____ ខែថ្មីដែលមើលមិនឃើញនោះទេ ។

៨. ពិធីបុណ្យ អ៊ីដូ អ៊ុល-ហ្វីត្វី ប្រព្រឹត្តិទៅក្នុងខែ_____________ ។ ចំណែកឯពិធីបុណ្យ អ៊ីដូ អ៊ុល អាដ្ហ្ហា ប្រព្រឹត្តិទៅក្នុងខែ_____________ ។

## លំហាត់ ៩

ក) វិញ្ញាប័នខាងក្រោមនេះជាទង្វើរបស់តាយ៉ាំមុម តែមិនស្របតាមលំដាប់ទេ ។ ចូររៀបឡើងវិញឲ្យត្រឹមត្រូវតាមលំដាប់របស់តាយ៉ាំមុម ។

១. យកបាតដៃទាំងពីរទះដីជាលើកទីពីរ ។
២. ជូតមុខចាប់ពីថ្ងាសរហូតដល់ចុងម្រុះ ។
៣. នៀត ។
៤. ជូតខ្នងដៃទាំងពីរជាលើកទីពីរ (ដៃស្ដាំ បន្ទាប់មក ដៃឆ្វេង) ។
៥. យកបាតដៃទាំងពីរទះដី ។
៦. ជូតខ្នងដៃទាំងពីរ ដៃស្ដាំមុនដៃឆ្វេង ។

ខ) ស្ថានភាពណាខ្លះដែលតម្រូវឲ្យធ្វើតាយ៉ាំមុម ។ ចូរលើកយកមកនូវស្ថានភាព ៣ ។

## លំហាត់ ៩

១. វត្ថុទាំងនេះជាវត្ថុដែលគេអនុញ្ញាតឲ្យយកតាយ៉ាំមុមលើបាន ។ ចូររៀបឲ្យសមតាមលំដាប់បុរិមា (ដែលគប្បីជាងតាមច្បាប់ស្ឆារីអ៊ុស្ស) ។

-ព្រឹល ឬ ទឹកកក ។
-ដុំថ្ម ។
-ជញ្ជាំងធ្វើអំពីដី ។
-ដី ។
-ធូលី ឬ ដីទទឹក ។
-ដីច្បាច់ ឬ ដីឥដ្ឋ ។

២. ចូរបំពេញចន្លោះទទេ ។

ក) នៅពេលធ្វើតាយ៉ាំមុមអ្នកត្រូវបញ្ជាក់ថាអ្នកធ្វើតាយ៉ាំមុមជូស______ឬ_____ ។

ខ) បើអ្នកមិនអាចធ្វើតាយ៉ាំមុមខ្លួនឯងបានទេ អ្នកអាច________ ។

គ) ពេលអ្នកធ្វើតាយ៉ាំមុម អ្វីៗដែលអាចជាឧបសគ្គ ដូចជា________ត្រូវតែយកចេញជាចាំបាច់ ។

ឃ) អ្វីដែលធ្វើឲ្យ___________ ឬ ___________មោឃៈនោះ ក៏ធ្វើឲ្យតាយ៉ាំមុមមោឃៈដែរ ។

ង) វត្ថុដែលអ្នកធ្វើតាយ៉ាំមុមលើត្រូវតែ___________ និង ___________ ។

កំណែលើកទី 2, 07/2020